សូមពុទ្ធបរិស័ទជ្រះថ្លាក្នុងដំណើរការសាងសង់ព្រះវិហារ

ប្លង់គម្រោងសាងសង់ព្រះវិហារ វត្តប្រាសាទស្រះកណ្តាល (ខ្ទាស់) ឃុំបុស្សរូ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ



រូបដែលសម្រេចបានពីការបុកគ្រឹះ



**សុខស្ស ទាតា មេធាវី សុខំ សោ អធិគច្ឆតិ**

ជនអ្នកមានប្រាជ្ញា បានឲ្យនូវសេចក្តីសុខដល់អ្នកដទៃ ជននោះនឹងបាននូវសេចក្តីសុខនោះមកខ្លួនវិញពុំខានឡើយ ។

ផ្សាយចេញពី វត្ត ប្រាសាទស្រះកណ្តាល (ខ្ទាស់)

ISBN-9789996331510

រោងពុម្ព ម៉ៅ ផុន
MAO PHON Printing House

យល់ដឹងពីការចេញវស្សា កឋិនទាន និងអានិសង្សលាភ ព្រះមហា ធម្មាលង្ការោ ចាន់ សុជន

# យល់ដឹងពីការចេញវស្សា

## កឋិនទាន និងអានិសង្សលាភ





រៀបរៀងដោយ

ព្រះមហា ធម្មាលង្ការោ **ចាន់ សុជន**

រក្សាសិទ្ធិ
Copyright © 2013

# យល់ដឹងពីការចេញវស្សា

## កឋិនទាន និងអានិសង្សលាភ

រៀបរៀងដោយ

ព្រះមហា ធម្មាលង្ការោ **ចាន់ សុជន**

រក្សាសិទ្ធិ
Copyright © 2013

# ពាក្យប្រារព្ធ

**កឋិនទាន** (កាលទាន) ជាទានពិសេសមួយ ក្នុងព្រះពុទ្ធសាសនា ដែលពុទ្ធសាសនិកទូទាំងពិភពលោក ក្នុងនោះមានពុទ្ធសាសនិកខ្មែរផងដែរ ដែលតែងតែនិយមដង្ហែកឋិនចីវរយកទៅវេរថ្វាយ ប្រគេនចំពោះព្រះភិក្ខុសង្ឃ ដែលលោកគង់ចាំវស្សាអស់ត្រីមាសបីខែក្នុងវត្តនោះៗ បានក្រាលគ្រងអនុមោទនាកឋិន។

ការចាត់ចែងនូវសំពត់ចីវរ របស់ទាយកទាយិកា ដើម្បីវេរថ្វាយចំពោះព្រះសង្ឃជាការងារសំខាន់មួយក្នុងការទ្រទ្រង់ និងបន្តអាយុជីវិត



ព្រះពុទ្ធសាសនា ពីព្រោះជាការងារទាក់ទងទៅនឹងព្រះវិន័យ។

ដោយសារមុនចូលវស្សា ខ្ញុំបានសរសេរសៀវភៅមួយក្បាលរួចទៅហើយ ដែលមានឈ្មោះថា " **យល់ដឹងពីការចូលវស្សា ដង្ហែទៀនវស្សា និងសាដក** " តែឥឡូវនេះ ខ្ញុំសូមដាក់ឈ្មោះសៀវភៅនេះថា " **យល់ដឹងពីការចេញវស្សា កឋិនទាន និងអានិសង្សលោក** " ស្របគ្នា នឹងបុណ្យកឋិនទានឈានមកដល់ផងនោះ សៀវភៅនេះ នឹងចែកជាធម្មទានក្នុងពិធីបុណ្យកឋិនទាន **វត្តប្រាសាទស្រះកណ្ដាល(ខ្នាស់)** ដែលប្រព្រឹត្តទៅនៅថ្ងៃ សៅរ៍-អាទិត្យ ១៤-១៥ កើត ខែ កត្តិក ព.ស. ២៥៥៧

*ត្រូវនឹង ថ្ងៃទី១៦-១៧ ខែវិច្ឆិកា ឆ្នាំ២០១៣ ។*

*ធ្វើនៅ វត្តសំពៅមាស(ភ្នំពេញ)*

*ថ្ងៃ ១១ កើត ខែ កត្តិក ព.ស. ២៥៥៧*

*រៀបរៀងដោយ ព្រះមហា* **ធម្មាលង្ការោ ចាន់ សុជន**


អាសយដ្ឋានៈ វត្តប្រាសាទស្រះកណ្តាល(ខ្ចាស់)
ឃុំបុស្បូវ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ
Address: Wat Prasat srahkandal(kchas)
Bosbov Commune, Preah Net Preah
District, Banteay Meanchey Province
ទូរស័ព្ទ: ០១២ ២២ ៨៥ ១២
គណៈកម្មការវត្ត ០៩៧ ៣៩៩ ៥៨ ៨៩
អាចារ្យវត្ត. ០៨៨ ៥៦៤ ១៨ ៥៨
E-mail: sochun_chan@yahoo.com
kchastemple@yahoo.com




## មាតិកា


| លេខរៀង | ទំព័រ |
|---|---|
| ពាក្យប្រារព្ធ ………………………………… | ក |
| **ការចេញវស្សារបស់ព្រះសង្ឃពុទ្ធសាសនា** | **១** |
| ក. មូលហេតុន័យការបវារណា(ចេញវស្សា) …… | ២ |
| ខ. កិច្ចបវារណាចេញវស្សា ………………… | ៦ |
| គ. ពិធីផ្សេងៗក្នុងឱកាសចេញវស្សា ………… | ១៦ |
| **កឋិន** ………………………………… | **១៨** |
| ក. និយមន័យ ……………………………… | ១៨ |
| ខ. ប្រភេទកឋិន ………………………… | ២២ |
| គ. បុព្វហេតុកឋិន ……………………… | ២៣ |
| ឃ.កាលទាន(កឋិនកាល) ………………… | ២៩ |

ង. លក្ខណៈប្លែក៥យ៉ាងរបស់កឋិន ………… ៣៣

ច. អានិសង្ស៥យ៉ាងរបស់ភិក្ខុក្រាលគ្រងអនុមោទនាកឋិន ៣៨

ឆ. អានិសង្សលាភ ……………………………… ៤២

**កឋិនទាននៅកម្ពុជា ……………………….... ៤៥**

ក. គម្រោងបុណ្យកឋិនទាន…………………….. ៤៦

ខ. វណ្ដាប់កឋិនទាន ………………………….. ៤៩

គ. កម្មវិធីកឋិន ………………………………… ៥២

ឃ. វិធីវេរកឋិន ………………………………….. ៥៦

ង. វិធីក្រាលកឋិន ……………………………….. ៦០

ច. ចីវរនិងរង្វាស់ខ្នាត …………………………. ៧៣

ឆ. អានិសង្សចីវរទាន …………………………. ៨៤

# ការចេញវស្សារបស់ព្រះសង្ឃពុទ្ធសាសនា

ភិក្ខុសង្ឃកាលបើបានចូលវស្សា និងបាននៅចាំវស្សាអស់ត្រីមាសហើយត្រូវធ្វើកិច្ចការចេញចាកការចាំវស្សារបស់ខ្លួន ហៅថា " **បវារណា** " ។ បវារណា ជាវេទិកាវិះគន់គ្នា ដើម្បីការរីកចម្រើន គឺភិក្ខុមួយរូបៗ ប្រកាសដាក់ខ្លួនដាក់កាយឲ្យសង្ឃ ឬឲ្យបុគ្គលគ្នាឯងជួយរិះគន់ ជួយពិនិត្យរកមើលកំហុសរបស់ខ្លួនក្រែងបានប្រព្រឹត្តផ្តាំផ្គងល្មើសលើបទបញ្ញត្តិណាមួយ ក្នុងឋិរវេលា នៃការចាំវស្សានោះ ទោះបានឃើញក្តី បានឮក្តី មានការរង្កៀសក្តី ក៏សូមឲ្យលើកឡើងបង្ហាញឲ្យបានច្បាស់ដើម្បី





បានដឹង ហើយធ្វើការកែប្រែឲ្យល្អឡើងវិញ ។

## ក. មូលហេតុនៃការបវារណា(ចេញវស្សា)

មូលហេតុដែលនាំឲ្យភិក្ខុសង្ឃពុទ្ធសាសនិកបវារណាចេញវស្សានោះមានដូចតទៅ ៖

សម័យមួយ ព្រះមានជោគទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋីជិតក្រុងសាវត្ថី ។ គ្រានោះមានភិក្ខុច្រើនរូបជាមិត្តទើបបានជួបគ្នាថ្មី(សន្ទិដ្ឋមិត្ត) ជាមិត្តស្និទ្ធស្នាលមាំមួន(សម្ភត្តមិត្ត) បានចូលវស្សាក្នុងអាវាសមួយក្នុងកោសលជនបទ ។ ភិក្ខុទាំងនោះ មានសេចក្តីត្រិះរិះថា តើយើងមានឧបាយដូចម្តេចដើម្បីនឹង

បានជាអ្នកព្រមព្រៀងគ្នា ស្មោះសរ មិនវិវាទគ្នា នៅចាំវស្សាឲ្យបានស្រួលផង មិនលំបាកដោយអាហារបិណ្ឌបាតផង? ភិក្ខុទាំងនោះក៏មានគំនិតឯកភាពថា « បើយើងមិននិយាយគ្នា មិនចរចាគ្នាទៅវិញទៅមក បើយើងត្រូវការពឹងគ្នាត្រូវប្រើកាយវិការជាសញ្ញា តែមិនត្រូវប្រើវាចាឡើយ ទើបយើងឈ្មោះថា ជាអ្នកព្រមព្រៀងគ្នា ស្មោះសរ មិនវិវាទគ្នា នៅចាំវស្សាក៏ស្រួលផង មិនលំបាកដោយអាហារបិណ្ឌបាតផង » ។ ពួកភិក្ខុទាំងនោះព្រមព្រៀងគ្នាដូច្នេះហើយ ក៏លែងស្តីហៅរក ឆ្លើយឆ្លងគ្នារហូតគ្រប់ខែបី ។

លុះចេញវស្សាហើយ ភិក្ខុទាំងនោះក៏រៀបចំទុកដាក់សេនាសនៈ ប្រដាប់ដោយបាត្រ និងចីវរចេញដំណើរទៅកាន់ក្រុងសាវត្ថី ដើម្បីចូលទៅគាល់ព្រះ-





មានព្រះភាគក្នុងវត្តជេតពន ។ ព្រះសាស្តាទ្រង់ត្រាស់ថា « ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយល្មមអត់ធន់សេចក្តីទុក្ខបានឬទេ? ល្មមឲ្យឥរិយាបថប្រព្រឹត្តទៅស្រួលបានឬទេ? អ្នកទាំងឡាយជាបុគ្គលព្រមព្រៀងគ្នា ស្រុះស្រួលគ្នា មិនទាស់ទែងគ្នា នៅចាំវស្សាដោយសប្បាយហើយឬ? មួយទៀត អ្នកទាំងឡាយមិនលំបាកដោយបិណ្ឌបាតទេឬ? ភិក្ខុទាំងនោះ ក៏ក្រាបទូលថា យើងខ្ញុំនៅចាំវស្សាដោយសប្បាយចិត្ត ព្រោះយើងខ្ញុំមានគំនិតឯកភាពគ្នា « យើងខ្ញុំ មិនគប្បីហៅរកគ្នា មិនគប្បីចរចារកគ្នាទៅវិញទៅមក នោះទើបឈ្មោះថាជាអ្នកព្រមព្រៀងគ្នា ស្រុះស្រួលគ្នា មិនទាស់ទែងគ្នា នៅចាំវស្សាដោយសប្បាយ » ។ ព្រះមានព្រះភាគទ្រង់សណ្តាប់ពាក្យនេះហើយ ក៏ទ្រង់មានព្រះ

បន្ទូលថា « ម្នាលភិក្ខុទាំងឡាយ អ្នកនៅចាំវស្សាមិនសប្បាយទេ ប៉ុន្តែប្តេជ្ញាថាខ្លួនជាអ្នកនៅចាំវស្សាដោយសប្បាយ អ្នកនៅចាំវស្សាដូចជាការរស់នៅរបស់បសុសត្វ (សត្វចិញ្ចឹម) ឬដូចជាការរស់នៅរបស់សត្វពពែ ឬក៏ដូចជាការរស់នៅរបស់បុគ្គលប្រមាទតែប្តេជ្ញាខ្លួនថា ជាអ្នករស់នៅដោយសប្បាយ ។ ម្នាលមោឃបុរស អ្នកមិនសមបើនឹងសមាទាននូវមូគវត្ត (វត្តរបស់មនុស្ស) ដែលជាតិត្ថិយសមាទាន (សមាទានរបស់តិរ្ថិយ) ទេ អំពើនេះ មិនមែននាំឲ្យគេជ្រះថ្លាទេ ។

ព្រះសម្ពុទ្ធទ្រង់បន្ទោសភិក្ខុទាំងនោះ យ៉ាងនេះ ហើយក៏ទ្រង់ធ្វើធម្មីកថា ថា « ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសមាទាននូវមូគវត្ត[១] ដែលជាតិត្ថិយសមាទាន

[១] ប្រព្រឹត្តមិននិយាយរកគ្នា





ទេ ភិក្ខុណាសមាទាន ត្រូវអាបត្តិទុក្កដ ។ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុទាំងឡាយដែលនៅចាំវស្សារួចហើយបវារណាដោយស្ថានបីយ៉ាង គឺ ដោយឃើញក្តី ដោយឮក្តី ដោយរង្កៀសក្តី = **អនុជានាមិ ភិក្ខវេ វស្សំ វុត្ថានំ ភិក្ខូនំ តីហិ ឋានេហិ បវារេតុំ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា ។**

## ខ. កិច្ចបវារណាចេញវស្សា

ជាទូទៅ នៅល្ងាច ឬយប់ថ្ងៃ ១៥ កើតខែអស្សុជ ព្រះសង្ឃដែលបានគង់ចាំបុរិមិកាវស្សាអស់ខែបីនៅក្នុងអាវាសណាមួយនោះ ត្រូវជួបជុំគ្នានៅក្នុងព្រះវិហារ នមស្សការព្រះរតនត្រ័យនិងសម្តែងអាបត្តិ។ បើមានភិក្ខុចាប់ពី ៥ អង្គ ឡើងទៅនៅចាំវស្សាក្នុង

អាវាសមួយ ត្រូវបវារណាយ៉ាងនេះ គឺ ជាបឋម សង្ឃត្រូវចាត់តាំងភិក្ខុដែលឈ្លាសប្រតិពល ឲ្យប្រកាសក្នុងជំនុំសង្ឃថា « ***សុណាតុ មេ ភន្តេ សង្ឃោ អជ្ជ បវារណា ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ បវារេយ្យ*** = បពិត្រព្រះសង្ឃដ៏ចម្រើនសូមព្រះសង្ឃស្តាប់ខ្ញុំ ថ្ងៃនេះជាថ្ងៃបវារណា ។ បើបវារណាកម្ម មានកាលគួរដល់សង្ឃហើយ គួរសង្ឃបវារណា » ។ ភិក្ខុជាថេរៈត្រូវអង្គុយច្រហោងផ្គងអញ្ជលី ហើយនិយាយយ៉ាងនេះនឹងសង្ឃថា « ***សង្ឃំ អាវុសោ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ ។ ទុតិយម្បិ អាវុសោ សង្ឃំ បវារេមិ ... បដិករិស្សាមិ, តតិយម្បិ អាវុសោ សង្ឃំ បវារេមិ ... បដិករិស្សាមិ*** = ម្នាលអាវុសោ ខ្ញុំសូម





បវារណានឹងសង្ឃ ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកមានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះហើយពោល (ដាស់តឿន) ចំពោះខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម ម្នាលអាវុសោខ្ញុំសូមបវារណានឹងសង្ឃ ជាគម្រប់ពីរដងផង ... នឹងធ្វើតាម, ម្នាលអាវុសោ ខ្ញុំសូមបវារណានឹងសង្ឃ ជាគម្រប់បីដងផង ... នឹងធ្វើតាម ។ ភិក្ខុដែលមានវស្សាខ្ចីបន្តបន្ទាប់ត្រូវអង្គុយច្រហោងផ្គងអញ្ជលីឡើង ហើយនិយាយយ៉ាងនេះនឹងសង្ឃថា « ***សង្ឃំ ភន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ ។ ទុតិយម្បិ ភន្តេ សង្ឃំ បវារេមិ ... បដិករិស្សាមិ, តតិយម្បិ ភន្តេ សង្ឃំ បវារេមិ ... បដិករិស្សាមិ*** = បពិត្រព្រះសង្ឃដ៏ចម្រើន

ខ្ញុំសូមបវារណានឹងសង្ឃ ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកម្ចាស់មានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះ ហើយពោល (ដាស់តឿន) ចំពោះខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម, បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំសូមបវារណានឹងសង្ឃអស់វារៈពីរដងផង ... នឹងធ្វើតាម, បពិត្រព្រះសង្ឃដ៏ចម្រើន ខ្ញុំសូមបវារណានឹងសង្ឃអស់វារៈបីដងផង ... នឹងធ្វើតាម ។ ត្រូវបវារណាបែបនេះតាមលំដាប់វស្សា មួយអង្គម្តងៗ រហូតគ្រប់អង្គ ។

បើមានភិក្ខុ ៤ អង្គក្តី ៣ អង្គក្តី នៅចាំវស្សាក្នុងអាវាសមួយ លុះពេលចេញវស្សា ត្រូវធ្វើបវារណាដល់គ្នានឹងគ្នា = ត្រូវភិក្ខុដែលឈ្លាស ប្រតិពលប្រកាសឲ្យភិក្ខុទាំងឡាយដឹងថា « **សុណន្តុ មេ អាយស្មន្តោ អជ្ជ**





**បវារណា ។ យទាយស្មន្តានំ បត្តកល្លំ មយំ អញ្ញមញ្ញំ បវារេយ្យាម** = សូមលោកមានអាយុទាំងឡាយស្តាប់ខ្ញុំ ថ្ងៃនេះជាថ្ងៃ បវារណា ។ បើបវារណា មានកាលគួរដល់លោកមានអាយុទាំងឡាយហើយ ត្រូវយើងទាំងឡាយបវារណាដល់គ្នានឹងគ្នា ។ បន្ទាប់មកត្រូវភិក្ខុជាថេរៈ គ្រងចីពរ អង្គុយច្រហោង ផ្គងអញ្ជលីរួចនិយាយយ៉ាងនេះថា « **អហំ អាវុសោ អាយស្មន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ ។ ទុតិយម្បិ អាវុសោ អាយស្មន្តេ បវារេមិ ... បដិករិស្សាមិ, តតិយម្បិ អាវុសោ អាយស្មន្តេ បវារេមិ ... បដិករិស្សាមិ** = ម្នាលអាវុសោ ខ្ញុំសូមបវារណានឹងលោកមានអាយុទាំងឡាយដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោក

*មានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះ និយាយ(ដាស់តឿន) ចំពោះខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម, ម្នាលអាវុសោ ខ្ញុំសូមបវារណានឹងលោកមានអាយុទាំងឡាយជាគម្រប់ពីរដងផង ... នឹងធ្វើតាម, ម្នាលអាវុសោ ខ្ញុំសូមបវារណានឹងលោកមានអាយុទាំងឡាយជាគម្រប់បីដងផង ... នឹងធ្វើតាម ។ រួចមកភិក្ខុខ្ចីវស្សាបន្តបន្ទាប់ ត្រូវនិយាយមួយអង្គម្តងៗរហូតដល់គ្រប់អង្គយ៉ាងនេះថា « **អហំ ភន្តេ អាយស្មន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សមិ ។ ទុតិយម្បិ ភន្តេ អាយស្មន្តេ បវារេមិ ... បដិករិស្សាមិ តតិយម្បិ ភន្តេ អាយស្មន្តេ បវារេមិ ... បដិករិស្សាមិ** = បពិត្រលោកដ៏ចម្រើន ខ្ញុំសូមបវារណានឹងលោក*





*មានអាយុទាំងឡាយ ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកមានអាយុទាំងឡាយ អាស្រ័យនូវសេចក្តីអនុគ្រោះ និយាយ(ដាស់តឿន) ខ្ញុំ កាលបើឃើញនឹងធ្វើតាម, បពិត្រលោកដ៏ចម្រើន ខ្ញុំសូមបវារណានឹងលោកមានអាយុទាំងឡាយ ជាគម្រប់ពីរដងផង ... នឹងធ្វើតាម, បពិត្រលោកដ៏ចម្រើន ខ្ញុំសូមបវារណានឹងលោកមានអាយុទាំងឡាយជាគម្រប់បីដងផង ... នឹងធ្វើតាម ។*

*បើមានភិក្ខុពីរអង្គ នៅចាំវស្សាក្នុងអាវាសមួយជាមួយគ្នា លុះពេលចេញវស្សា ត្រូវបវារណាយ៉ាងនេះ គឺភិក្ខុដែលមានវស្សាចាស់ជាង ត្រូវគ្រងចីពរអង្គុយច្រហោង ផ្គងអញ្ជលីហើយនិយាយនឹងភិក្ខុខ្ចីវស្សាជាងថា « **អហំ អាវុសោ អាយស្មន្តំ បវារេមិ***

ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទេតុ មំ អាយស្មា អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ ។ ទុតិយម្បិ អាវុសោ អាយស្មន្តំ បវារេមិ ... បដិករិស្សាមិ, តតិយម្បិ អាវុសោ អាយស្មន្តំ បវារេមិ ... បដិករិស្សាមិ = ម្នាលអាវុសោ ខ្ញុំសូមបវារណានឹងលោកមានអាយុ ដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកមានអាយុ អាស្រ័យនូវសេចក្តីអនុគ្រោះ និយាយ(ដាស់តឿន) ខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម, ម្នាលអាវុសោ ខ្ញុំសូម បវារណានឹងលោកមានអាយុជា គម្រប់ពីរដងផង ... នឹងធ្វើតាម, ម្នាលអាវុសោ ខ្ញុំសូមបវារណានឹងលោក ដ៏មានអាយុជាគម្រប់បីដងផង ... នឹងធ្វើតាម ។ រួចហើយ ភិក្ខុខ្ចីវស្សា ត្រូវនិយាយនឹងភិក្ខុចាស់វស្សា ថា « អហំ ភន្តេ អាយស្មន្តំ បវារេមិ ទិដ្ឋេន វា សុតេន វា





បរិសង្កាយ វា វទេតុ មំ អាយស្មា អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ ។ ទុតិយម្បិ ភន្តេ អាយស្មន្តំ បវារេមិ ... បដិករិស្សាមិ តតិយម្បិ ភន្តេ អាយស្មន្តំ បវារេមិ ... បដិករិស្សាមិ = បពិត្រលោកដ៏ចម្រើន ខ្ញុំសូមបវារណា នឹងលោកដ៏ចម្រើនដោយឃើញក្តី ឮក្តី រង្កៀសក្តី សូមលោកមានអាយុអាស្រ័យនូវសេចក្តី អនុគ្រោះនិយាយ(ដាស់តឿន) ខ្ញុំ កាលបើខ្ញុំឃើញ នឹងធ្វើតាម, បពិត្រលោកដ៏ចម្រើន ខ្ញុំសូមបវារណានឹង លោកមានអាយុជាគម្រប់ពីរដងផង ... នឹងធ្វើតាម, បពិត្រលោកដ៏ចម្រើន ខ្ញុំសូមបវារណានឹងលោកមាន អាយុជាគម្រប់បីដងផង ... នឹងធ្វើតាម ។

បើមានភិក្ខុតែមួយអង្គគត់ គង់ចាំវស្សាក្នុងអា-វាសមួយ លុះដល់ថ្ងៃត្រូវបវារណាចេញវស្សា ត្រូវធ្វើ

យ៉ាងនេះ គឺបោសប្រាសសម្អាតទីកន្លែងដែលខ្លួននៅចាំវស្សានោះ ឲ្យស្អាតបាត ដងទឹកតម្កល់ទុក ក្រាលអាសនៈ អុជប្រទីបអង្គុយរង់ចាំមើល ក្រែងមានភិក្ខុពីអាវាសដទៃមកបវារណាជាមួយ ប៉ុន្តែបើរង់ចាំទៅហើយឃើញថាគ្មានទេ ត្រូវអធិដ្ឋានថា « **អជ្ជ មេ បវារណា** = ថ្ងៃនេះ ជាថ្ងៃបវារណា របស់អញ » តែប៉ុណ្ណោះជាការស្រេច ។ បើមិនបានអធិដ្ឋានបែបនេះទេ ត្រូវអាបត្តិទុក្កដ = **នោ ចេ អធិដ្ឋហេយ្យ អាបត្តិ ទុក្កដស្ស** ។

ពុទ្ធបំណងនៃការបវារណា គឺដើម្បីឲ្យព្រះសង្ឃស្រឡាញ់រាប់អានគ្នា ។ កាលបើអ្នកណាមួយបានឃើញ បានឮ ឬរង្កៀស អំពីការប្រព្រឹត្តខុសឆ្គងរបស់គ្នា ត្រូវរំឭកដាស់តឿនគ្នា ដើម្បីឲ្យប្រព្រឹត្តល្អស្មើគ្នា





ជាព្រះសង្ឃដ៏ល្អនៅជាសុខរួមគ្នារហូតទៅ មិនត្រូវមើលបំណាំចាំតែចាប់ទោសកំហុសគ្នា ហើយបែរមុខចេញ មិនសេពគប់រាប់រកគ្នានោះឡើយ ព្រោះអាការដែលមើលបំណាំគ្នា ថ្កោលទោសគ្នាយ៉ាងនោះ ជាហេតុឲ្យព្រះសង្ឃមិនសាមគ្គីគ្នា ដែលមិនជាទីជ្រះថ្លាដល់ពួកបរិស័ទ ជាហេតុធ្វើឲ្យពុទ្ធសាសនាថយចុះរោយរៀវផង។

## គ. ពិធីផ្សេងៗ ក្នុងឱកាសចេញវស្សា

ថ្ងៃបវារណា ជាថ្ងៃបញ្ចប់កិច្ចនៅចាំវស្សារបស់ភិក្ខុសង្ឃ ដែលលោកអត់ទ្រាំមិនត្រាច់ទៅកាន់ទីឆ្ងាយខិតខំរៀនសូត្រស្វាធ្យាយធម៌វិន័យក្នុងគន្ថធុរៈ និងចម្រើនមេត្តា ភាវនា ក្នុងវិបស្សនាធុរៈ ចំនួនបីខែកន្លង

ទៅ ។ ហេតុនេះហើយ បានជាឧបាសក ឧបាសិកា ជ្រះថ្លាខ្លាំងក្លានាំគ្នាធ្វើបុណ្យសុន្ទរ៍ទានផ្សេងៗ ទុកដូចជាពិធីសម្ពោធឆ្លងបុណ្យចាំវស្សារបស់ព្រះសង្ឃ ។





# កឋិន

**ក. និយមន័យ**

ពាក្យថា "**កឋិន**" ជាភាសាបាលី សំដៅយកក្របក្តារ ដែលភិក្ខុសង្ឃ សម័យបុរាណតណ្ហាប្រើសម្រាប់ដេរសំពត់ធ្វើជាស្បង់ចីវរ ។ សំពត់ដែលបានរៀបចំតាក់តែងឡើងនោះមានឈ្មោះថា "**សំពត់កឋិន**" ។

តាមអដ្ឋកថា សំដៅយកព្រះពុទ្ធដីកាដែលព្រះពុទ្ធទ្រង់បានបញ្ញត្តទុកមកថា **កឋិន** គឺការប្រជុំរួបរួមនូវ រូបធម៌ និងនាមធម៌ ដែលប្រព្រឹត្តទៅក្នុងអត្ថន័យពីរយ៉ាង៖

១- **រស់បានដោយកម្រ** សមដូចវិគ្គហៈ ថា ៖ "**កថតិ កិច្ចេន ជីវតីតិ កឋិនោ**" ។ ប្រែថា "សភាវៈឯណារស់បានដោយកម្រ សភាវៈនោះហៅថា **កឋិន** ។ ព្រោះលោកប្រៀបប្រដូចជាឈើស្ងួតដែលបុគ្គលកាត់ចាកចេញពីដើម ហើយយកទៅបោះភ្ជាប់នឹងដី រមែងដុះលូតលាស់ ឬរស់នៅបានដោយកម្រយ៉ាងណា ឯកិច្ចដែលនឹងកើតឡើង ឬតាំងឡើង ជាកឋិនពេញទី គឺបានដោយកម្រ ពន់ពេកណាស់ ក៏យ៉ាងនោះដែរ" ។

២- **ពោលសរសើរ** ព្រោះចីវរទានដែលយើងកសាង ជាកឋិននោះ ជាទានវិសេសជាងទានដទៃ ដែលព្រះអរិយទាំងឡាយ មាន





ព្រះសម្ពុទ្ធជាប្រធាន តែងពោលសរសើរថា ជាទានដ៏វិសេស អាចរួបរួម ឬក៏សង្គ្រោះនូវអានិសង្ស ៥យ៉ាង របស់ភិក្ខុអ្នកក្រាលគ្រង់ មិនឲ្យទៅគ្រង់នៅទីដទៃបាន ។ សមដូចវិគ្គហៈ ថា៖ "**បញ្ច អានិសំសេ អញ្ញត្ថ គន្តុំ អទត្វា កថេតិ សង្គណ្ហាតីតិ កឋិនំ**" ។ ប្រែថា "ធម្មជាតឯណាក្រៀកទុក ឬសង្គ្រោះនូវអានិសង្សទាំង ៥យ៉ាង មិនឲ្យទៅក្នុងទីដទៃបាន ធម្មជាតនោះ ឈ្មោះថា **កឋិន**" ។

**កឋិននេះ** អាចឲ្យសម្រេចផលដល់បុគ្គលទាំងពីរផ្នែកគឺ៖

១- ទាយកឬទាយិកា គឺជាអ្នកឲ្យ ។ ជននោះរមែងទទួលអានិសង្សច្រើន ទទួលផលច្រើនក្នុងអនាគតកាល មានការទទួលនូវសម្បត្តិក្នុងឋានទេវលោក ជាដើម ។

២- បដិគ្គាហកៈ ភិក្ខុ ឬបុគ្គល ឬសង្ឃជាអ្នកទទួលក្រាលគ្រង និងអនុមោទនាកឋិន ត្រូវបានសម្រេចនូវអានិសង្ស៥យ៉ាង ពេញលេញគ្រប់គ្រាន់ ដរាបដល់រយៈកាលនៃកឋិនខេត្ត ។

ពិធីដែល ទាយក ទាយិកា នាំយកសំពត់កឋិនទៅប្រគេនចំពោះភិក្ខុសង្ឃ ដែលបានគង់ចាំវស្សាអស់មួយត្រៃមាស(បីខែ) ក្នុងអាវាស(វត្ត)ណាមួយនិងនៅពេលណាមួយ ក្នុងកំណត់ ២៩





ថ្ងៃ (ចាប់ពីថ្ងៃ១រោច ខែអស្សុជ រហូតដល់ថ្ងៃ ១៥កើត ពេញបូណ៌មី ខែកត្តិក) ឲ្យលោកក្រាលគ្រងមានឈ្មោះថា "**បុណ្យកឋិន**" ឬ "**កឋិនទាន**" ។

**ខ. ប្រភេទកឋិន**

កឋិនមាន៣ប្រភេទគឺ ៖

១- **សាមញ្ញកឋិនៈ** ទម្រង់កឋិនធម្មតា គឺនាំយកសំពត់កឋិន ដែលគេធ្វើស្រាប់ហើយ ទៅប្រគេនភិក្ខុសង្ឃ ។

២- **មហាកឋិនៈ** យកសំពត់សមួយផ្ទាំងទៅកាត់ដេរ និងជ្រលក់ពណ៌ តែមួយថ្ងៃ ដើម្បីឲ្យកើតជាសំពត់កឋិន ។

៣- **ចុល្លកឋិនៈ** ទាក់ទងតាំងពី រវៃកប្បាសធ្វើជាអម្បោះ ត្បាញអម្បោះធ្វើជាកំណាត់សំពត់ ហើយកាត់ដេរ និងជ្រលក់កំណាត់ឲ្យកើតជាសំពត់កឋិន យ៉ាងពិបាក ។

**គ. បុព្វហេតុកឋិន**

វិន័យបិដក ភាគ៨ កឋិនក្ខន្ធកៈ (ទំព័រ១) បានចែងអំពីបុព្វហេតុនៃបុណ្យកឋិនថា ៖ "ក្នុងសម័យពុទ្ធកាល ព្រះសម្ពុទ្ធទ្រង់ពុទ្ធានុញ្ញាតឲ្យ





ភិក្ខុប្រើប្រាស់ តែបង្សុកូលចីវរ ព្រះអង្គពុំទាន់បានពុទ្ធានុញ្ញាតឲ្យប្រើគហបតិចីវរនៅឡើយ ។

នាសម័យមួយនោះ នៅក្នុងរវាង មជ្ឈិមពោធិកាលព្រះសម្ពុទ្ធទ្រង់កំពុងតែចាំព្រះវស្សាក្នុងវត្តជេតពន ដែលជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី សាងថ្វាយ នៅទៀបក្រុងសាវត្ថី ។ គ្រានោះមានភិក្ខុ៣០រូប "**ភទ្ទវគ្គិយត្ថេរ**" ក្នុងដែន បាវេយ្យ ជាអ្នកប្រព្រឹត្តធម៌ធុតង្គរុក្ខមូល នៅក្នុងព្រៃបាននាំគ្នានិមន្តចេញពីទីនោះ មកកាន់ក្រុងសាវត្ថី ដើម្បីនឹងចូលក្រាបបង្គំគាល់ព្រះសម្ពុទ្ធ ។ ប៉ុន្តែ ពេលភិក្ខុទាំងអស់បានមកដល់តែត្រឹម សាកេត (ភូមិមួយ នៅជាប់នឹងក្រុងសាវត្ថី) ស្រាប់តែថ្ងៃចូល

វស្សាក៏មកដល់នឹងស្រូតមកទៀតមិនទាន់ ក៏នាំគ្នាផ្អាកធ្វើដំណើរ ស្វែងរកទីសេនាសនៈ នៅចាំវស្សា ៣ខែ នាទីនោះតែម្តងទៅ ។

ភិក្ខុសង្ឃទាំង៣០រូបនោះ មានសេចក្តីអផ្សុក កើតទុក្ខតូចព្រះទ័យយ៉ាងខ្លាំង ដោយគិតឃើញថា ព្រះសម្ពុទ្ធ ទ្រង់គង់នៅទីនោះ ចម្ងាយត្រឹមតែ ៦យោជន៍ (៩៦គីឡូម៉ែត្រ) ទៀតសោះ មិនសមយើងទាំងឡាយស្ទុនដំណើរ មិនបានចូលគាល់បម្រើព្រះអង្គដូចបំណង ។

លុះដល់ថ្ងៃចេញវស្សា បវារណា ស្រេចហើយ ភិក្ខុទាំងអស់ក៏នាំគ្នា ប្រញាប់ប្រញាល់ចូលកាន់ក្រុងសាវត្ថី ។ លុះដល់ហើយ ភិក្ខុទាំង





៣០រូប ក៏បានចូលទៅក្រាបថ្វាយបង្គំគាល់ព្រះសម្មាសម្ពុទ្ធ ដោយមានស្បង់ចីវរទទឹកជោក ។ ព្រះមានព្រះភាគទ្រង់មានព្រះបន្ទូលរួសរាយ រាក់ទាក់និងត្រាស់សួរសុខទុក្ខភិក្ខុទាំងនោះថា៖ "ម្នាលភិក្ខុទាំងឡាយ! តើសរីរយន្តរបស់អ្នកទាំងឡាយល្មមអត់សង្កត់បានឬទេ? ល្មមប្រព្រឹត្តទៅបានឬទេ? តើអ្នកទាំងឡាយ មានសេចក្តីព្រមព្រៀងស្មោះស្មើ ឥតមានវិវាទទាស់ទែងគ្នា ទេឬ?"

ភិក្ខុទាំងឡាយនោះ ក៏ក្រាបបង្គំទូល នូវសេចក្តីលំបាកខ្លាំងរបស់ខ្លួន ក្នុងការធ្វើដំណើរដែលមានមកតាមផ្លូវដោយសព្វគ្រប់ប្រការ ។

លំដាប់នោះ ព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងនូវធម្មីកថា ប្រារព្ធអំពីសង្សារវដ្ដ មិនមានទីបំផុត ប្រោសប្រទានដល់ភិក្ខុទាំងនោះ ។ លុះចប់ធម៌ហើយ ភិក្ខុទាំងឡាយនោះ បានសម្រេចព្រះអរហត្តផលគ្រប់ៗអង្គ រួចហើយក៏នាំគ្នាក្រាបថ្វាយបង្គំលាព្រះសម្ពុទ្ធចៀសចេញទៅ ។

លំដាប់តអំពីនោះមក ព្រះសម្ពុទ្ធទ្រង់ព្រះពុទ្ធចិន្ដាថា៖ "ប្រសិនបើតថាគត បានអនុញ្ញាតនូវកឋិនត្ថារកិច្ច ដល់ភិក្ខុទាំងឡាយ ទុករួចពីគ្រាមុនមក ម៉្លេះសមភិក្ខុទាំង៣០រូបនេះ បានលះសង្ឃាដីមួយទុកនៅកន្លែង ហើយយកជាប់មកជាមួយខ្លួនតែចីវរមួយ ស្បង់មួយប៉ុណ្ណោះ មានអត្តភាព





ស្រាលមិនលំបាកតាមផ្លូវ យ៉ាងនេះសោះឡើយ ។ រីឯកឋិនត្ថារកិច្ចនេះសោត ព្រះពុទ្ធទាំងឡាយគ្រប់ព្រះអង្គក៏ធ្លាប់បានអនុញ្ញាតដល់សាវ័ក ពុំដែលលះបង់ផង" ។

លុះព្រះសម្ពុទ្ធទ្រង់ព្រះតម្រិះ យ៉ាងដូច្នេះហើយ ទើបទ្រង់ត្រាស់ឲ្យប្រជុំភិក្ខុទាំងឡាយ រួចហើយទ្រង់អនុញ្ញាតនូវកឋិនត្ថារកិច្ចដល់ភិក្ខុទាំងឡាយថា៖ "**អនុជានាមិ ភិក្ខវេ វស្សំ វុត្ថានំ ភិក្ខូនំ កឋិនំ អត្ថរិតុំ អត្ថតកឋិនានំ វោ ភិក្ខវេ បញ្ច កប្បិស្សន្តិ**" ។

ប្រែថា: "ម្នាលភិក្ខុទាំងឡាយ! តថាគតអនុញ្ញាត ឲ្យភិក្ខុទាំងឡាយដែលនៅចាំវស្សារួច

ហើយ ទទួលក្រាលគ្រង់កឋិនបាន ។ ម្នាលភិក្ខុទាំងឡាយ! អានិសង្ស៥ប្រការ នឹងសម្រេចដល់ភិក្ខុទាំងឡាយ ដែលអ្នកបានក្រាលគ្រង់ និងបានអនុមោទនាកឋិន រួចហើយនោះ” ។

**ឃ. កឋិនកាល**(**កាលទាន**)

ចីវរកឋិន មិនខុសប្លែកគ្នាអំពី ចីវរទាន ដទៃទៀតទេ គ្រាន់តែការធ្វើបុណ្យកឋិនចីវរ មានកំណត់កាលបរិច្ឆេទច្បាស់លាស់ និងមានប្រជាប្រិយភាពច្រើន ដែលហៅថា “ កឋិនកាល ឬ កាលទាន ”





ព្រះសម្ពុទ្ធទ្រង់ពុទ្ធានុញ្ញាត ឲ្យភិក្ខុសង្ឃទទួលស្បង់ចីវរអំពីពុទ្ធបរិស័ទ និង គហបតីទាំងឡាយ ក្នុងពេលមួយខែ កំណត់ពីថ្ងៃ១រោចខែអស្សុជ ដល់ថ្ងៃ១៥កើត ពេញបូណ៌មី ខែកត្តិក (ក្នុងរវាងពាក់កណ្តាលខែតុលា ដល់ពាក់កណ្តាលខែវិច្ឆិកា) ។ ព្រះសម្ពុទ្ធ ទ្រង់ព្រះមេត្តាប្រោសអនុញ្ញាត ដល់ភិក្ខុសង្ឃ ជាអ្នកក្រាលគ្រង់ និងអនុមោទនាកឋិននោះ បានទទួលអានិសង្ស៥ប្រការ ។

ជនមានសទ្ធា ដែលបានធ្វើកឋិនទានឈ្មោះថា ជាអ្នកបានគោរពនូវព្រះពុទ្ធដីកា ដែលទ្រង់បានពុទ្ធានុញ្ញាតឲ្យភិក្ខុសង្ឃ បានទទួលអានិសង្ស

៥ប្រការផង ជាអ្នកមានចិត្តអាណិតអាសូរចំពោះភិក្ខុសង្ឃ ដែលបានគង់ចាំវស្សាអស់ត្រៃមាសនោះផង និងជាអ្នកតអាយុព្រះពុទ្ធសាសនា អស់កាលជាអង្វែងទៅផង ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់សម្តែងជាគាថា យ៉ាងនេះថាៈ " **សុខស្ស ទាតា មេធាវី សុខំ សោ អធិគច្ឆតិ**" ។ ប្រែថា: "ជនដ៏មានប្រាជ្ញា (ណាមួយ) បានឲ្យនូវសេចក្តីសុខស្រួល (ដល់អ្នកដទៃ) ជននោះឯង រមែងបានជួបប្រទះនឹងសេចក្តីសុខស្រួល(ជាពិតប្រាកដពុំដែលខានឡើយ) " ។

សេចក្តីអធិប្បាយ ជាយ៉ាងនេះថាៈ " ជនណាបានធ្វើកឋិនទាន ដែលនាំឲ្យភិក្ខុសង្ឃបាន





ទទួលអានិសង្ស៥យ៉ាង ក្នុងរវាង៥ខែ បានឈ្មោះថា ជាអ្នកឲ្យសេចក្តីសុខស្រួលដល់អ្នកដទៃ ក្នុងបច្ចុប្បន្នជាតិ ជននោះឯងតែងបានសុខក្នុងមនុស្សលោក និងទេវលោក ក្នុងអនាគត ។ ដោយអំណាចផលានិសង្ស នៃកឋិនទាននោះ ក្នុងអនាគតកាល ជននោះនឹងបានជាឯហិភិក្ខុ មានត្រៃចីវរកើតឡើងឯកឯង ដោយឫទ្ធិ នៅពេលបព្វជ្ជាជាបព្វជិតនៅក្នុងសាសនា ព្រះពុទ្ធអង្គណាមួយ ហើយក៏នឹងបានសម្រេចមគ្គផល និព្វាន ក្នុងពេលបព្វជ្ជានោះ ពុំខានឡើយ" ។

តាំងពីពេលនោះតរៀងមក បុណ្យកឋិនបានក្លាយជាបុណ្យទំនៀមមួយ របស់ពួកពុទ្ធ-

បរិស័ទ ដើម្បីបំពេញនូវសេចក្តីត្រូវការស្បង់ចីវរដ៏វិសេសនេះ ។

**ខ. លក្ខណៈប្លែក ៥ យ៉ាង**

បុណ្យកឋិន មានលក្ខណៈប្លែក ៥យ៉ាង អំពីបុណ្យផ្សេងៗ និងក្លាយជាបុណ្យដ៏មានសារៈសំខាន់នៅក្នុងវត្តពុទ្ធសាសនា និងក្នុងចំណោមពុទ្ធបរិស័ទទូទៅ ។

១- ប្លែកដោយកាល

ព្រះពុទ្ធទ្រង់ពុទ្ធានុញ្ញាតកឋិនកាលមានតែចំនួន ២៩ថ្ងៃ គឺ៖ ១៤ថ្ងៃ ក្នុងខែអស្សុជ (កំណត់





ពីថ្ងៃ១រោច រហូតដល់ថ្ងៃ១៤រោច ឬខែដាច់) និង ១៥ថ្ងៃ ក្នុងខែកត្តិក (កំណត់ពីថ្ងៃ១កើត រហូតដល់ថ្ងៃ១៥កើតពេញបូណ៌មី) ។ រយៈពេលនេះ ហៅតាមពាក្យសាមញ្ញថា "**រដូវកឋិន**" ។

បុណ្យកឋិន ធ្វើបានតែម្តងគត់ ក្នុងមួយឆ្នាំសម្រាប់វត្តមួយ និងត្រូវធ្វើតាមកំណត់ មិនមានមុន មិនមានក្រោយ ។ ភិក្ខុទទួលសំពត់កឋិនបានតែម្តងគត់ ក្នុងមួយរដូវកឋិន ។

២- ប្លែកដោយវត្ថុ

សំពត់ដែលជាអង្គកឋិននោះ មាន ស្បង់ចីវរ និងសង្ឃាដី ដែលបានធ្វើត្រឹមត្រូវតាមពុទ្ធបញ្ញត្តិ ។

យោងតាមវិនយបញ្ញត្តិ ទោះបីជា ទាយក ទាយិកា នាំយកសំពត់មួយត្រៃ មកប្រគេនភិក្ខុសង្ឃ ក៏ភិក្ខុសង្ឃអ្នកក្រាលគ្រង់លោករើសយកតែមួយមុខ មកធ្វើជាអង្គកឋិន ។ តាមធម្មតា ភិក្ខុច្រើនតែរើសយកសង្ឃាដី ធ្វើជាអង្គកឋិន ពីព្រោះសង្ឃាដី ជាសំពត់ធំជាងគេបង្អស់ក្នុងត្រៃចីវរ ហើយអាចប្រើសម្រាប់ដណ្តប់ ដូចជាភួយនៅពេលរងាក៏បាន ។

៣- ប្លែកដោយអំពើ

តាមទំនៀមទម្លាប់ ពុទ្ធបរិស័ទតែងមានជំនឿថា ការធ្វើបុណ្យចំពោះភិក្ខុមួយអង្គៗ ពុំសូវ





បានអានិសង្សច្រើនដូចធ្វើនឹងសង្ឃទេ (សង្ឃសំដៅយកភិក្ខុ៤អង្គឡើងទៅ) ។

យោងតាម វិនយបញ្ញត្តិ អង្គកឋិន អាចវេរប្រគេនចំពោះសង្ឃ យ៉ាងហោចណាស់ក៏មានវត្តមានភិក្ខុ៥អង្គដែរ ដើម្បីឲ្យកើតជាកឋិនពេញលក្ខណៈបាន ។

៤- ប្លែកដោយអ្នកទទួល (បដិគ្គាហកៈ)

មានតែភិក្ខុទេ ដែលអាចទទួលសំពត់កឋិនបាន(រីឯសាមណេរ និងអ្នកដទៃទទួលពុំបាន) ។ ភិក្ខុនោះត្រូវតែគង់ចាំវស្សាអស់ត្រៃមាសគម្រប់ ៣ ខែ ក្នុងវត្តឬអាវាសណាមួយ ។ ភិក្ខុមិនគង់ចាំ

វស្សាគ្មានសិទ្ធិទទួលក្រាលគ្រងអង្គកឋិនទេ ។

## ៥- ប្រែកដោយអានិសង្ស

យោងតាមវិន័យបិដក ភាគ៨ ត្រង់កឋិនក្ខន្ធកៈ ភិក្ខុសង្ឃ ដែលជាអ្នកក្រាលគ្រង និងអនុមោទនាកឋិន ត្រូវបានទទួល អានិសង្ស ៥យ៉ាង ក្នុងរយៈពេល៥ខែ គឺតាំងពីថ្ងៃ១រោច ខែអស្សុជ ដល់ថ្ងៃ១៥កើត ខែផគ្គុណ(នេះចំពោះតែភិក្ខុដែលបានក្រាល អនុមោទនាកឋិន ពីថ្ងៃ១រោច ខែអស្សុជ) ។





## ច. អានិសង្ស ៥ យ៉ាង

### ទី១- អនាមន្តចារោ

អានិសង្សទី១នេះ អាចធ្វើឲ្យភិក្ខុ ដែលជាអ្នកបានក្រាលគ្រង និងអនុមោទនាកឋិន រួចចាកអាបត្តិ ក្នុង**ចារិត្តសិក្ខាបទ**ទី៦ និងក្នុង**អចេលកវគ្គ នៃសុទ្ធិកបាចិត្តិយៈ**បាន ។ ក្នុងអដ្ឋកថាបានពន្យល់ថា កឋិននៅមិនទាន់ដោះ ដរាបណាការដែលភិក្ខុមិនបានលាភិក្ខុផងគ្នា ជាមុនសិន ហើយត្រាច់ទៅកាន់ទីដទៃ នឹងមិនមានទោស ឬត្រូវអាបត្តិ ក្នុងចារិត្តសិក្ខាបទទី៦ ដរាបនោះ ។

### ទី២- **អសមាទានចារោ**

អានិសង្សទី២នេះ អាចធ្វើឲ្យភិក្ខុ ដែលជាអ្នកបានក្រាលគ្រង់ និងអនុមោទនាកឋិន រួចចាកអាបត្តិ ក្នុង**ទុតិយកឋិនសិក្ខាបទទី២** ក្នុង**ចីវរវគ្គ** នៃ**និស្សគ្គិយបាចិត្តិយៈ**បាន ។ ក្នុងអដ្ឋកថាបានពន្យល់ថា ការដែលភិក្ខុត្រាច់ទៅកាន់ទីដទៃដោយមិនបានកាន់យកនូវ សំពត់ណាមួយ ឬត្រៃចីវរគ្រប់ប្រដាប់ជាប់ជាមួយខ្លួន នឹងមិនមានទោស ឬត្រូវអាបត្តិក្នុង ទុតិយកឋិនសិក្ខាបទទី២ ឡើយ ។

### ទី៣- **គណភោជនំ**

អានិសង្សទី៣នេះ អាចធ្វើឲ្យភិក្ខុ ដែលជាអ្នកបានក្រាលគ្រង់ និងអនុមោទនាកឋិន រួចចាក





អាបត្តិ ក្នុង**គណភោជនសិក្ខាបទទី២** ក្នុង**ភោជនវគ្គ**នៃ**សុទ្ធិកបាចិត្តិយៈ**បាន ។ ក្នុងអដ្ឋកថាពន្យល់ថា ភិក្ខុអាចឆាន់គណភោជនបាន នឹងមិនមានទោស ឬត្រូវអាបត្តិក្នុងគណភោជនសិក្ខាបទទី២ ឡើយ ។

### ទី៤- **យាវទត្ថចីវរំ**

អានិសង្សទី៤នេះ អាចធ្វើឲ្យភិក្ខុ ដែលជាអ្នកបានក្រាលគ្រង់ និងអនុមោទនាកឋិន រួចចាកអាបត្តិ ក្នុង**បឋមកឋិនសិក្ខាបទទី១** ក្នុង**ចីវរវគ្គ** នៃ**និស្សគ្គិយបាចិត្តិយៈ**បាន ។ ក្នុងអដ្ឋកថាពន្យល់ថា ភិក្ខុអាចទុកអតិរេកចីវរ (ចីវរលើសអំពីសេចក្តីត្រូវការ) កន្លងពី១០ថ្ងៃចំនួនប៉ុន្មានក៏បាន ទោះបីមិន

បានអធិដ្ឋាន មិនបានវិកប្ប ក៏នឹងមិនមានទោស ឬត្រូវអាបត្តិ ក្នុងបឋមកឋិនសិក្ខាបទទី១ ឡើយ។

ទី៥- *យោ ច តត្ថ ចីវរុប្បាទោ សោ នេសំ ភវិស្សតិ*

អានិសង្សទី៥នេះ អាចធ្វើឲ្យភិក្ខុ ដែលជាអ្នកបានក្រាលគ្រង និងអនុមោទនាកឋិន មានអំណាចទទួលចំណែកលាភ ដែលកើតឡើងក្នុងអាវាស ដែលខ្លួនចាំវស្សាបាន ។ ក្នុងអដ្ឋកថាបានពន្យល់ថា ចីវរជារបស់សង្ឃកើតឡើងក្នុងឧបចារសីមាដែលក្រាលកឋិននោះ ទោះបីកើតឡើងដោយអាការបែបណាក៏ដោយ ក៏ចីវរទាំងនោះ





នឹងត្រូវបានដល់ភិក្ខុជាអ្នកបានក្រាលគ្រង និងអនុមោទនាកឋិនគ្រប់រូបនោះឯង ។

**ឆ. អំពីអានិសង្សលាភ**

អដ្ឋកថា ប្រាប់ថា កាលបើភិក្ខុក្រាលកឋិនយ៉ាងនេះហើយ បើទាយកវេរប្រគេនសំពត់ជាអានិសង្សលាភ ដែលគេនាំមកជាមួយនឹងចីវរកឋិនដោយពាក្យថា *យេន អម្ហាកំ កឋិនំ គហិតំ តស្សេវ ទេម* " កឋិនរបស់យើងខ្ញុំ លោកអង្គណាទទួល យើងខ្ញុំសូមវេរប្រគេនចំពោះ លោកអង្គនោះ " ដូច្នេះភិក្ខុសង្ឃមិនបានជាឥស្សរៈឡើយ បើលុះតែគេមិនបានចាត់ចែងដូច្នោះ គេគ្រាន់តែវេរប្រគេន

*ហើយត្រឡប់ទៅផ្ទះវិញ ទើបភិក្ខុសង្ឃបានជាឥស្សរៈ ។ ព្រោះហេតុនោះ បើចីវរដ៏សេសទាំងប៉ុន្មានរបស់ភិក្ខុអ្នកក្រាលកឋិន ជាចីវរទុព្វលភាព ហើយសំពត់ជា អានិសង្សលាភរបស់កឋិនមានច្រើន (បើសង្ឃបានជាឥស្សរៈ) សង្ឃគប្បីអបលោកប្រគេនសំពត់បន្ថែម ទៅលោកអ្នកក្រាលនោះទៀត ដើម្បីប្រយោជន៍ធ្វើចីវរទាំងនោះ ប៉ុន្តែការសូត្រកម្មវាចាតែម្តងក៏គួរហើយ ។ ឯសំពត់កឋិនានិសង្សលាភដែលសេសសល់ពីនោះ បើមានច្រើន ត្រូវប្រគេនតាំងអំពីអាសនៈនៃព្រះថេរៈចុះមក ឯគ្រឿងគរុភណ្ឌ មិនត្រូវចែកគ្នាឡើយ ។*





*ក្នុង**គម្ពីរវិនយាលង្ការដីកា** លោកបានពន្យល់អំពីការចែកអានិសង្សលាភ ឲ្យកាន់តែទូលាយឡើងទៀតថា[២] អកាលចីវរដែលសង្ឃតម្កល់ទុកក្នុងឃ្លាំង សង្ឃត្រូវបែងចំណែកពាក់កណ្តាលចែកឲ្យសាមណេរទាំងឡាយ ឯសំពត់ចំណាំវស្សា និងសំពត់ជាកឋិនានិសង្សជាដើម ដែលជាកាលចីវរ ក៏ត្រូវសង្ឃចែកឲ្យសាមណេរឲ្យស្មើគ្នានឹងភិក្ខុដែរ[៣] ។*

---

[២] **ភណ្ឌាគារេ ឋបិតំ ហិ អកាលចីវរមេវ សាមណេរានំ ឧបឌ្ឍបដិវិសំ កត្វា កាតព្វំ វស្សាវាសិកកឋិនានិសំសាទិកាលចីវរំ បន សមកមេវ កាតព្វំ ។**

[៣] ចំពោះសាមណេរដែលបានចូលវស្សា ឯសាមណេរដែលពុំបានចូលវស្សាទេ សង្ឃគួរសង្គ្រោះចែកឱ្យដោយ**អបលោកនកម្ម** ឬបើមិនឱ្យសោះ ក៏ឥតមានកំហុស អ្វីឡើយ ។

## កឋិនទាននៅកម្ពុជា

កឋិនទានក្នុងជំនាន់ពុទ្ធកាល ហាក់ដូចជាងាយនឹងធ្វើសោះ ទោះបីជនក្រីក្រ ខ្វះខាត ថ្នាក់ទាបបំផុតក៏ដោយ ឲ្យតែមានស្បង់ ១ ឬចីពរ ១ ឬសង្ឃាដី ១ ឬមានសំពត់ត្រឹមតែពីរ ឬបីម៉ែត្រ ក៏អាចយកទៅវេរចំពោះព្រះសង្ឃ ដែលគង់ចាំវស្សាអស់ត្រីមាសក្នុងវត្តណាមួយ ក៏ឈ្មោះថាជាអ្នកបានធ្វើកឋិនហើយ ប៉ុន្តែ បុណ្យកឋិនទាននៅកម្ពុជា លុះណាតែអ្នកមានស្តុកស្តម្ភ ឬគ្នាច្រើន ទើបអាចធ្វើកឋិនកើត ព្រោះកឋិននៅកម្ពុជាពុំមែនមានត្រឹមតែស្បង់ ១ ឬចីពរ ១ ឬសង្ឃាដី ១





ប៉ុណ្ណោះទេ គឺត្រូវមានបរិក្ខារដ៏ច្រើនផ្សេងៗទៀតជាពិសេស បច្ច័យសង្កត់ត្រៃសម្រាប់កសាងវត្តអារាម និងសមិទ្ធិសាធារណៈ មានសាលារៀន មន្ទីរពេទ្យ ជាដើម ។

### ក- គម្រោងបុណ្យកឋិនទាន

កាលណាថ្ងៃ បវារណាចេញវស្សា របស់ព្រះសង្ឃជិតមកដល់ ពុទ្ធបរិស័ទគ្រប់ជើងវត្តនានាក្នុងប្រទេសកម្ពុជាទាំងមូលតែងតែ ពិភាក្សាគ្នា ដើម្បីធ្វើកឋិនទានប្រគេនព្រះសង្ឃគ្រប់វត្តអារាម តាមស្ម័គ្ររៀងខ្លួន ដោយមានជំនឿជាប់មកជាទំនៀមថា កឋិនទាន ជាកាលទានមានផលានិសង្សច្រើនជាងទានទាំងពួង គឺអ្នកធ្វើ

ក៏បានអានិសង្ស អ្នកទទួលក៏បានអានិសង្ស ។ ជំនឿនេះបានចាក់ឫសជាប់នៅក្នុងចិត្តថ្លើមរបស់ពុទ្ធសាសនិកជនទូទាំងប្រទេស រហូតដល់សម្គាល់វត្តដែលដល់រដូវកឋិនហើយ គ្មាននរណាហែកឋិនចូល ជាវត្តមិនស្មើមុខនឹងវត្តដែលមាន ។ ដូច្នេះហើយបានជាវត្តណា ដែលគ្មានពុទ្ធបរិស័ទក្រៅជើងវត្តហែកឋិនចូល ពុទ្ធបរិស័ទជាចំណុះជើងវត្តនោះ តែងស្ទុះស្ទា អង្គាសគ្នាធ្វើទាល់តែកើតជាអង្គកឋិនទានឡើង មិនទុកឲ្យទំនេរឡើយ ។ បុណ្យកឋិននេះ មិនមែនត្រឹមតែជាទំនៀមទម្លាប់របស់ប្រជារាស្ត្រប៉ុណ្ណោះទេ សូម្បីតែព្រះរាជា រាជរដ្ឋាភិបាលកម្ពុជា ក៏តែងតែទ្រង់ធ្វើ





និងចូលរួមពុំដែលអាក់ខានឆ្នាំណាឡើយ ។

អ្នកមានធនធានច្រើន ដែលមានបំណងនឹងធ្វើកឋិនដង្ហែទៅវេរប្រគេនព្រះសង្ឃ ក្នុងវត្តណាមួយ តែងតែសុំ ឬឲ្យដំណឹងទៅព្រះសង្ឃ ឬអាចារ្យវត្តនោះដឹងជាមុន ជាពិសេសតាំងពីក្នុងវស្សាម៉្លេះ ថាខ្លួនហែកឋិនទានមកកាន់វត្តនោះនៅថ្ងៃនេះ ឬថ្ងៃនោះពុំខាន ។ ឯពុទ្ធបរិស័ទចំណុះជើងវត្តនីមួយៗ ក៏តែងតែទន្ទឹងរង់ចាំដំណឹងតាំងពីក្នុងវស្សាដែរ ថាតើវត្តរបស់ខ្លួនមានភ័ព្វវាសនា នឹងបានទទួលកឋិនទានរបស់លោកអ្នកណា? កឋិនទាននោះឱឡារិក ធំដុំ ឬក៏តូចតាចល្មមទេ?

## ខ- វណ្ដាប់កឋិនទាន

បន្ទាប់ពីបានសម្រេចថា នឹងរៀបចំធ្វើជាអង្គកឋិនហើយ អ្នកសាមីដើមទានតែងតែខ្វល់ខ្វាយពឹងពាក់លោកអាចារ្យ ឬ ព្រឹទ្ធាចារ្យ ដែលធ្លាប់យល់ដឹង ឬធ្លាប់មានពិសោធន៍ ក្នុងការរៀបគ្រឿងវណ្ដាប់កឋិន ឲ្យជួយចាត់ចែងរៀបចំ ឲ្យបានត្រឹមត្រូវតាមទម្លាប់ និងក្រឹត្យក្រមព្រះវិន័យ ។

ទំនៀមរបស់ប្រជារាស្ត្រកម្ពុជា ក្នុងការរៀបវណ្ដាប់អង្គកឋិនទានមានដូចខាងក្រោម ៖

- វណ្ដាប់អង្គកឋិន ១ សម្រាប់, សម្រាប់ប្រគេនព្រះថេរៈ ១ អង្គ ដែលក្រាលគ្រង គឺ ស្បង់ ១ ចីពរ ១ សង្ឃាដី ១ អង្សៈ ១ វត្ថពន្ធចង្កេះ ១





វត្ថពន្ធទ្រូង ១ និសីទនៈ ១ ឆ័ត្រ ១ បាត្រ ១ កំសៀវទឹក ១ កន្ទេល ១ ខ្នើយ ១ មុង ១ ក្អួយ ១ គ្រែ ១ ផ្ទាំង ចាន ស្លាបព្រា ...។

- វណ្ដាប់ញត្តិ ឬវណ្ដាប់គ្រូសូត្រឆ្វេង ស្ដាំ ២ សម្រាប់, សម្រាប់ប្រគេនព្រះថេរៈ ២ អង្គ ដែលសូត្រញត្តិ គឺមានចីវរ ១ លៀង (ស្បង់ ១ ចីពរ ១) និងបរិក្ខារមួយចំនួនទៀត ...។

វណ្ដាប់បរិក្ខារច្រើនសម្រាប់, សម្រាប់ប្រគេនព្រះភិក្ខុសង្ឃបរិស័ទ ដែលគង់ហត្ថបាសអនុមោទនាកឋិន ។ វណ្ដាប់នេះ គេនិយមរៀបធ្វើជាកញ្ចប់ ហើយក្នុងកញ្ចប់នេះមានជាអាទិ៍, ស្បង់ ឬសាដក ១ ទៀន ធូប តែ ស្ករ បារី ឈើគូស

ប្រាស ថ្នាំដុសធ្មេញ ថ្នាំពេទ្យ សាប៊ូ សៀវភៅ ប៊ិច ខ្មៅដៃ (ប្រាក់) ...។ វណ្ណាប់នេះ គេអាចធ្វើឲ្យមានចំនួនច្រើន សម្រាប់ប្រគេនសាមណេរផង ប្រសិនបើវត្តនោះមានសាមណេរ ។ ក្រៅពីវណ្ណាប់ទាំងបីផ្នែកនេះ អ្នកសាមីដើមទាន តែងប្រកាសបវារណានូវប្រាក់មួយចំនួន សម្រាប់ប្រគេនព្រះសង្ឃផ្ទាល់ និងមួយចំនួនធំសម្រាប់កសាងសមិទ្ធិផ្សេងៗ ដូចជា កុដិ វិហារ ស្រះ ខ្លោងទ្វារ របងវត្ត សាលារៀន មន្ទីរពេទ្យ ...។ បណ្ដាបរិក្ខារទាំងអស់នៃកឋិនទាន និយាយសរុបមានតែពីរយ៉ាងគឺស្បង់ ១ ចីពរ ១ ឬ សង្ឃាដី ១ ប៉ុណ្ណោះ ជាកឋិនចីវរ គឺចីវរដែលភិក្ខុ





ត្រូវក្រាលនិងបរិក្ខារ ក្រៅពីនេះហៅថា អានិសង្ស-លាភ ។

**គ- កម្មវិធីកឋិន**

បណ្ដា ២៩ ថ្ងៃ គឺពីថ្ងៃ ១រោច ខែអស្សុជ ដល់ថ្ងៃ ១៥កើត ខែកត្តិក បើអ្នកសាមីដើមទាន ស្ម័គ្រថ្ងៃណាមួយហើយ គេតែងតែបោះជាកម្មវិធីផ្សព្វផ្សាយចែកចាយដល់ញាតិមិត្ត ជិតឆ្ងាយ ដើម្បីឲ្យចូលរួមក្នុងពិធីបុណ្យកឋិន របស់គេ ។ សម័យបច្ចុប្បន្ន គេចូលចិត្តកំណត់កម្មវិធីនេះឲ្យត្រូវលើថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ គឺសូត្រមន្តថ្ងៃសៅរ៍ ដង្ហែថ្ងៃអាទិត្យ ។

ថ្ងៃសូត្រមន្ត, ថ្ងៃសូត្រមន្តជាថ្ងៃទី ១ នៃពិធីបុណ្យកឋិនទាន ដែលគេនិយមធ្វើនៅវេលា

ល្ងាច ។ ល្ងាចនោះ នៅគេហដ្ឋានអ្នកសាមីដើមកឋិនទាន គេសង្កេតឃើញមាន ៖

- ពិធីទទួលបដិសណ្ឋារៈ យ៉ាងអធិកអធម ដោយភោជនាហារយ៉ាងពោរពាស ចំពោះភ្ញៀវជិតឆ្ងាយ ដែលអញ្ជើញមកចូលបច្ច័យចាប់កុសលជាមួយ ។

- ពិធីចម្រើនព្រះបរិត្ត និងសម្តែងធម៌ទេសនា ។

- ជូនកាលមានសម្តែងសិល្បៈ ជូនភ្ញៀវកម្សាន្តផង ។

- នៅក្នុងវត្តដែលទទួលអង្គកឋិនទាន ក៏មានពិធីសូត្រមន្ត ទេសនាដែរ





ថ្ងៃដង្ហែ ឬថ្ងៃថត ជាថ្ងៃទី២ នៃកឋិនទាន ដែលគេនិយមធ្វើនៅពេលព្រឹក ។ ព្រឹកនេះ គេសង្កេតឃើញ ៖

- ការជួបជុំគ្នា នៅផ្ទះអ្នកសាមីដើមទានឡើងរថយន្តចូលរួមដង្ហែអង្គកឋិនទាន ឆ្ពោះទៅកាន់វត្តដែលបានគ្រោងទុក ។

- ពេលដង្ហែ គេសង្កេតឃើញនៅជាប់ នឹងមុខរថយន្ត នៃអង្គកឋិនទានមាន ចងបដាអក្សរធំៗ ថា « កឋិនទានដង្ហែទៅកាន់វត្ត ... » ។

- នៅលើរថយន្ត មានក្រុមឆៃយ៉ាំ ឡកលេងប្រគំកំដរ លាន់ឮរំពងរហូតដល់វត្ត ។

- នៅឯវត្តអារាមវិញ គេបានរៀបចំបោសប្រាសយ៉ាងស្អាត តុបតែងលម្អដោយទង់ជ្វាលា ទង់ជាតិ ទង់សាសនា រំយោលផ្កាភ្ញីយ៉ាងល្អល្អះព្រោងព្រាត ។

- បន្ទាប់ពីប្រគេនភត្តាហារ និងពិធីទទួលអង្គកឋិន និងជូនភោជនាហារចំពោះភ្ញៀវមកមានពិធីដង្ហែអង្គកឋិនប្រទក្សិណព្រះវិហារជាទក្ខិណាវ័ត៌(បត់ពីឆ្វេងទៅស្តាំ) ដោយមានក្រុមឆៃយ៉ាំប្រគំឡកលេងរាំយោងមុខយ៉ាងក្រមិចក្រមើម គួរឲ្យសប្បាយរីករាយជ្រះថ្លា បន្ទាប់មក មានលោកអាចារ្យនាំមុខអ្នកដើមទានទូលត្រៃធំ រណ្តាប់សូត្រឆ្វេង ស្តាំ និងកាន់រណ្តាប់បរិក្ខារផ្សេងៗ ។ រួច





ហើយចូលទៅតម្កល់ក្នុងកណ្តាលព្រះវិហារ ចំ-ពោះព្រះភក្ត្រព្រះពុទ្ធបដិមា និងព្រះភិក្ខុសង្ឃ ។ ពេលនោះ មានពិធីនមស្សការព្រះរតនត្រ័យ សមាទានសីល ប្រកាសបច្ច័យសង្កត់ត្រៃវេរអង្គកឋិនចំពោះព្រះសង្ឃ ពិធីក្រាលកឋិន ព្រះសង្ឃសូត្រធម៌អនុមោទនាឲ្យពរសាធុការ ដល់សាមីដើមទាន និងសប្បុរសជនទាំងអស់ ។

### ឃ- វិធីវេរអង្គកឋិន

តាមទម្លាប់របស់លោក អាចារ្យដែលជាអ្នកតំណាងម្ចាស់កឋិន តែងវេរអង្គកឋិនចំពោះព្រះសង្ឃតាមវិធីពីរយ៉ាងស្រេចហើយលើការចូលចិត្តរបស់ខ្លួន ៖

- **វិធីវេរបែបទី១** បើគេយកសាច់សំពត់សុទ្ធមកវេរចំពោះព្រះសង្ឃ ដើម្បីក្រាលកឋិននោះ លោកអាចារ្យតែងវេរថា « **នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស** (បីដង) ។ **ឥមំ ទុស្សំ កឋិនំ សង្ឃស្ស ទេម, ទុតិយម្បិ ឥមំ ... ទេម, តតិយម្បិ ឥមំ ... ទេម,** = យើងខ្ញុំទាំងឡាយ សូមវេរនូវសំពត់នេះដើម្បីកឋិនចំពោះព្រះសង្ឃ អស់វារៈពីរដងផង អស់វារៈបីដងផង » ។

- បើគេយកចីវរធ្វើស្រេចមកវេរចំពោះព្រះ-សង្ឃ ដើម្បីក្រាលកឋិននោះ លោកអាចារ្យតែងវេរថា « **នមោ តស្ស ភគវតោ អរហតោ សម្មា-សម្ពុទ្ធស្ស** (បីចប់) **ឥមំ កឋិនចីវរំ សង្ឃស្ស ទេម,**





**ទុតិយម្បិ ឥមំ ... ទេម, តតិយម្បិ ឥមំ ... ទេម,** = យើងខ្ញុំទាំងឡាយ សូមវេរនូវកឋិនចីវរនេះចំពោះព្រះសង្ឃ អស់វារៈពីរដងផង អស់វារៈ បីដងផង ។

- ប្រសិនបើមានបរិក្ខារផ្សេងៗ ក្រៅពីសំពត់កឋិន ឬកឋិនចីវរផងដែលហៅថា អានិសង្សលាភនោះ លោកអាចារ្យតែងវេរបន្ថែមទៀតថា « **យេ-នម្ហាកំ កឋិនំ គហិតំ កឋិនានិសំសានិ តស្សេវ ទេម, ទុតិយម្បិ យេនម្ហាកំ ... ទេម, តតិយម្បិ យេនម្ហាកំ ... ទេម** = រីកឋិននៃយើងខ្ញុំទាំងឡាយ គឺលោកម្ចាស់អង្គណាទទួលកាន់យក យើងខ្ញុំទាំងឡាយ សូមវេរនូវបរិក្ខារទាំងឡាយ ជាអានិសង្សលាភនៃកឋិនចំពោះលោកម្ចាស់អង្គនោះឯង ។ អស់

វារៈពីរដងផង ។ អស់វារៈបីដងផង ។

- ***វិធីវេរបែបទី ២ សម័យបច្ចុប្បន្ន*** លោកអាចារ្យគ្រប់វត្តនិយមវេរស្មើរតែទូទៅថា *នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស* (បីចប់) ។ ***មយំ ភន្តេ ឥមំ កឋិនចីវរំ សានិសំសំ សង្ឃស្ស ទេម***[៤] ***បដិគ្គណ្ហាតុ កឋិនំ អត្ថរិតុំ មាតាបិតាទីនំ គុណវន្តានញ្ច អម្ហាកញ្ច ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ, ទុតិយម្បិ មយំ ភន្តេ ... ហិតាយ សុខាយ, តតិយម្បិ មយំ ភន្តេ ... ហិតាយ សុខាយ*** = បពិត្រព្រះសង្ឃដ៏ចម្រើន យើងខ្ញុំទាំងឡាយសូមវេរនូវកឋិនចីវរព្រមទាំងអានិសង្សលាភនេះចំពោះព្រះ-

[៤]បទ **មយំ** ជាពហុវចនៈ ឧត្តមបុរិសៈ ហេតុនោះកិរិយាត្រូវប្រើ "ទេម" ដាក់បញ្ចូលមក ដើម្បីឲ្យមានកិរិយាទទួលបទប្រធាន ហើយពេញប្រយោគ ។





សង្ឃដើម្បីក្រាលកឋិន បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃមេត្តាទទួលនូវកឋិនចីវរ ព្រមទាំងអានិសង្សលាភនេះ ដើម្បីក្រាលកឋិន ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់លោកអ្នកមានគុណទាំងឡាយ មានមាតាបិតាជាដើមផង ដល់ខ្ញុំព្រះករុណាទាំងឡាយផង អស់កាលជាយូរអង្វែងទៅហោង អស់វារៈពីរដងផង អស់វារៈបីដងផង ។

### ខ- វិធីក្រាលកឋិន

ចំណែកព្រះសង្ឃ កាលបើបានទទួលកឋិនចីវរនោះដោយពិនិត្យពិច័យ ឃើញថាត្រឹម-

ត្រូវតាមវិន័យសព្វគ្រប់ហើយ ក៏ អប[៥]លោកឲ្យភិក្ខុ ១ រូប ដែលជំនុំសង្ឃយល់ថា គួរក្រាលកឋិនបាន រួចចាត់ភិក្ខុ ២ រូបសូត្រញត្តិ ជាភាសាបាលីប្រគល់ចីវរនោះ ដែលមានលំដាប់លំដោយដូចតទៅ ៖

- ដំបូង ភិក្ខុ ១ រូបដែលហៅថា «សូត្រឆ្វេង» ចាប់ផ្ដើមក្រើនកឋិនដោយពាក្យថា « ភន្តេ បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន រីអង្គកឋិនទាននេះ ជារបស់លោក(...) និង (...) សុទ្ធសឹងជាពុទ្ធមាមកជនប្រកបដោយបសាទសទ្ធា និងកុសលចេតនា ជាអសង្ខារិក ជ្រះថ្លាចំពោះគុណព្រះរតនត្រ័យ បាន

(៥) អានថា= អៈ ប៉ៈ លោក មានន័យថា "ប្រកាសពាក្យសុំសេចក្ដីយល់ព្រមអំពីជំនុំសង្ឃឬពីក្រុមជំនុំ ដើម្បីបង្វែរ ឬប្រគល់អ្វីឲ្យដល់អ្នកណាមួយ ។





បំពេញនូវបុញ្ញកិរិយាវត្ថុចេះលៃលកយកធនធានដែលគ្មានខ្លឹមសារ ធ្វើឲ្យជារបស់មានខ្លឹមសារកប់ទុកក្នុងព្រះពុទ្ធសាសនា ដើម្បីជាទ្រព្យមត៌កសម្រាប់ប្រើប្រាស់ទៅក្នុងភពខាងមុខទៀត បានស្រុះស្រួល បបួលគ្នាផ្ដួចផ្ដើមបង្កើតជាអង្គកឋិនទាននេះឡើង ដើម្បីយកមកវេរថ្វាយភិក្ខុសង្ឃដែលគង់ចាំវស្សាអស់ត្រៃមាសក្នុងទីវត្ត (...) នេះ ។ ដូច្នេះ សំពត់កឋិននេះហាក់ដូចជាសំពត់ទិព្វកោសេយ្យពស្ត្រ អណ្ដែតត្រសែតព្វដ៏អាកាសវេហាស៍នភាល័យ ហើយធ្លាក់ចុះមកក្នុងកណ្ដាលជំនុំសង្ឃ ជាសង្ឃទានដ៏ស្មោះឥតចំពោះព្រះករុណាអង្គណាមួយឡើយ ។ ហេតុនេះហើយ បើព្រះ

ករុណា មានត្រៃចីវរទុព្វលភាពដាច់ដាចមិនអាចប្រើប្រាស់បាន ហើយចេះនូវអានិសង្ស ៥ [៦]

មាតិកា៨ បលិពោធ២ អនត្ថតាការៈ ២៤ អត្ថតាការៈ ១៧ អាចញុំាងសង្ឃឲ្យគ្រេកអរដោយកឋិនត្ថារកិច្ចបាន ក៏សូមមានដីកាឆ្លើយមកចុះព្រះសង្ឃនឹងអបលោក សំពត់កឋិននេះ ដល់ព្រះករុណាអង្គនោះ ដោយញត្តិទុតិយកម្មវាចាក្រាលគ្រងតទៅ ។ (ពេលដែលភិក្ខុរូបនេះប្រកាសចប់ ត្រូវឈប់បង្អង់ ២ ឬ ៣ នាទី ដើម្បីរង់ចាំមើលក្រែងមានភិក្ខុរូបណា ដែលមានចីវរដាច់ដាច ឆ្លើយថាខ្លួនចង់ក្រាលកឋិននេះ) ។

(៦) មាននិយាយពិស្តារនៅក្នុងវិន័យបិដកភាគទី ៨





- បើគ្មានភិក្ខុរូបណាមាន ឆ្លើយថាខ្លួនសុំក្រាលកឋិននេះទេ ភិក្ខុ ១ រូប ទៀតដែលហៅថា « សូត្រស្តាំ » ត្រូវប្រកាសក្រើនកឋិនដោយពាក្យថា « ភន្តេ បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើន ខ្ញុំព្រះករុណាជាអ្នកតំណាងសង្ឃគ្រប់អង្គ ក្នុងឱកាសនេះ សូមពិតព្រះពុទ្ធដីកាចំពោះព្រះសង្ឃគ្រប់អង្គសូមទានជ្រាប ។ យើងខ្ញុំទាំងអស់សុទ្ធសឹងតែមានចីវរល្អមគ្រប់គ្រាន់ប្រើប្រាស់ហើយ ប៉ុន្តែតាមយោបល់របស់ខ្ញុំព្រះករុណាយល់ឃើញថា មានតែព្រះតេជគុណ (...) អង្គនេះ ទើបសមគួរនឹងក្រាលគ្រងនូវសំពត់កឋិននេះ ព្រោះលោកជាអ្នកចេះនូវអានិសង្ស ៥ ចាំនូវមាតិកា ៨ បលិពោធ ២

*អនត្ថតាការៈ ២៤ អត្ថតាការៈ ១៧ ហើយធ្មៀវ-ឆ្លាសក្នុងកឋិនត្ថារកិច្ច អាចញ៉ាំងសង្ឃឲ្យត្រេកអរបាន ។ ហេតុនេះ បើព្រះសង្ឃគ្រប់អង្គយល់-ឃើញថា សមគួរដូចជាបកាសនវាចា ដែលខ្ញុំព្រះករុណា បានថ្លែងមកនេះ ក៏សូមបញ្ចេញនូវសទ្ទសញ្ញាថា សាធុ ឲ្យព្រមៗគ្រប់អង្គទៅហោង ។ (ពេលនោះជំនុំសង្ឃក៏ទទួលព្រមៗគ្នាថា «សាធុ»។*

*- បន្ទាប់មក លោកអ្នកសូត្រទាំងពីររូបអង្គុយប្រហោងទឹមគ្នាលើកដៃប្រណម្យ ឆ្ពោះទៅរកភិក្ខុដែលត្រូវក្រាលគ្រង ដោយសូត្របាលីញត្តិទុតិយកម្មវាចា ថា «* [៧]***សុណាតុ មេ ភន្តេ***

(៧)វិន័យបិដកភាគទី ៨ ទំព័រ ៤





***សង្ឃោ ឥទំ សង្ឃស្ស កឋិនទុស្សំ ឧប្បន្នំ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥមំ កឋិនទុស្សំ (ឥត្ថន្នាមស្ស)***[៨] ***ភិក្ខុនោ ទទេយ្យ កឋិនំ អត្ថរិតុំ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥទំ សង្ឃស្ស កឋិនទុស្សំ ឧប្បន្នំ ។ សង្ឃោ ឥមំ កឋិនទុស្សំ (ឥត្ថន្នាមស្ស) ភិក្ខុនោ ទេតិ កឋិនំ អត្ថរិតុំ ។ យស្សាយស្មតោ ខមតិ ឥមស្ស កឋិនទុស្សស្ស (ឥត្ថន្នាមស្ស) ភិក្ខុនោ ទានំ កឋិនំ អត្ថរិតុំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទិន្នំ ឥទំ សង្ឃេន កឋិនទុស្សំ (ឥត្ថន្នាមស្ស) ភិក្ខុនោ កឋិនំ អត្ថរិតុំ ។ ខមតិ***

[៨] គ្រប់បទថា (ឥត្ថន្នាមស្ស) ត្រូវដាក់ឈ្មោះភិក្ខុអ្នកក្រាលកឋិន

**សង្ឃស្ស តស្មា តុណ្ហី ឯវមេតំ ធារយាមិ** = បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ ដ្បិតសំពត់កឋិននេះកើតឡើងដល់ សង្ឃហើយ ។ បើកម្មមានកាលសមគួរដល់សង្ឃ ហើយគួរសង្ឃឲ្យសំពត់កឋិននេះដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីនឹងក្រាលកឋិន ។ នេះជាញត្តិ។ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃស្តាប់ខ្ញុំ ដ្បិតសំពត់កឋិននេះកើតឡើងដល់សង្ឃហើយ ។ ឥឡូវ សង្ឃឲ្យសំពត់កឋិននេះដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីនឹងក្រាលកឋិន ។ ការឲ្យសំពត់កឋិន នេះដល់ភិក្ខុ (ឈ្មោះនេះ) ដើម្បីនឹងក្រាលកឋិន បើគួរដល់លោកមានអាយុអង្គណា ត្រូវលោកមានអាយុអង្គ





នោះស្ងៀម បើមិនគួរដល់លោកមានអាយុអង្គណាទេត្រូវលោកមានអាយុអង្គនោះ និយាយឡើង ។ សំពត់កឋិននេះ សង្ឃឲ្យដល់ភិក្ខុឈ្មោះនេះ ដើម្បីនឹងក្រាលកឋិនហើយ ។ ការឲ្យសំពត់កឋិននេះ គួរដល់សង្ឃហើយ ព្រោះហេតុនេះបានជាសង្ឃស្ងៀម ។ ខ្ញុំសូមចាំទុកនូវការនេះដោយអាការៈនៅស្ងៀមយ៉ាងនេះ ។

- ភិក្ខុអ្នកក្រាល ត្រូវសូត្របាលីដកសង្ឃាដីចីពរ ស្បង់ចាស់ចេញថា « **ឥមំ សង្ឃាដឹ បច្ចុទ្ធរាមិ** = អាត្មាអញដកនូវសង្ឃាដីនេះ ។ **ឥមំ ឧត្តរាសង្គំ បច្ចុទ្ធរាមិ** = អាត្មាអញដកនូវចីពរនេះ ។ **ឥមំ អន្តរវាសកំ បច្ចុទ្ធរាមិ** = អាត្មាអញ ដកនូវស្បង់

នេះ ។

- ភិក្ខុអ្នកក្រាល ត្រូវយកខ្មៅដៃធ្វើកប្បពិន្ទុ ត្រង់មុមចីវរ ដែលបម្រុងក្រាល (គឺធ្វើជាចំណុចមួយមូលដូចជាពងកូនឃ្មី) ដោយបាលីថា « **ឥមំ ពិន្ទុកប្បំ ករោមិ** = អាត្មាអញធ្វើនូវពិន្ទុកប្បនេះ »។

- ភិក្ខុអ្នកក្រាលត្រូវអធិដ្ឋានចីវរថ្មីថា « **ឥមំ អន្តរវាសកំ អធិដ្ឋាមិ ។ ទុតិយម្បិ ... តតិយម្បិ ...** = អាត្មាអញអធិដ្ឋាននូវស្បង់នេះ អស់វារៈពីរដងផង, អស់វារៈបីដងផង ។ **ឥមំ ឧត្តរាសង្គំ អធិដ្ឋាមិ, ទុតិយម្បិ ... តតិយម្បិ ...** អាត្មាអញអធិដ្ឋាននូវចីវរនេះ អស់វារៈពីរដងផង, អស់វារៈបីដងផង ។ **ឥមំ សង្ឃាដឹ អធិដ្ឋាមិ ទុតិយម្បិ ... តតិយម្បិ ...** =





អាត្មាអញអធិដ្ឋាននូវសង្ឃាដីនេះ អស់វារៈពីរដងផង, អស់វារៈបីដងផង ។

- ភិក្ខុអ្នកក្រាល ត្រូវដោះសង្ឃាដីចាស់ ចីពរចាស់ ស្បង់ចាស់ចេញ ហើយទ្រង់[៩] ស្បង់ថ្មី ចីពរថ្មី សង្ឃាដីថ្មី រួចគង់បត់ព្រះបាទលើកព្រះហស្តសំពះជំនុំសង្ឃៗ សំពះតបវិញ ហើយប្រកាសប្រាប់ជំនុំសង្ឃថា « **ឥមាយ សង្ឃាដិយា កឋិនំ អត្ថរាមិ** = ខ្ញុំក្រាលកឋិនដោយសង្ឃាដីនេះ (បើចង់យកសង្ឃាដីជាសំពត់កឋិន) ។ **ឥមិនា ឧត្តរាសង្គេន កឋិនំ អត្ថរាមិ** = ខ្ញុំក្រាលកឋិនដោយចីពរនេះ (បើចង់យកចីពរជាសំពត់កឋិន) ។

(៩) ស្លៀកពាក់

**ឥមិនា អន្តរវាសកេន កឋិនំ អត្ថរាមិ** = ខ្ញុំក្រាលកឋិនដោយស្បង់នេះ (បើចង់យកស្បង់ជាសំពត់កឋិន) ។

- ភិក្ខុអ្នកក្រាល ត្រូវអង្គុយប្រហោង ប្រណម្យអញ្ជលីឆ្ពោះទៅរកសង្ឃ ឬគណៈ ឬបុគ្គល (ដែលបានគង់ចាំវស្សាជាមួយគ្នា) ហើយពោលថា « **អត្ថតំ អាវុសោ**[១០] **សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ អនុមោទថ (អនុមោទាហិ)** ម្នាលអាវុសោ កឋិនរបស់សង្ឃ ខ្ញុំក្រាលហើយ ការក្រាលកឋិន (នេះ) ប្រកបដោយធម៌ សូមលោកទាំងឡាយអនុមោទនាចុះ ។

[១០] បើមានអ្នកអនុមោទនាចាស់វស្សាជាង ភិក្ខុអ្នកក្រាលត្រូវពោថា « ភន្តេ » វិញ ។





- ភិក្ខុអ្នកអនុមោទនា ត្រូវអង្គុយប្រហោងប្រណម្យអញ្ជលីពោលថា « **អត្ថតំ ភន្តេ សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ អនុមោទាម** បពិត្រលោកម្ចាស់ដ៏ចម្រើន កឋិនរបស់សង្ឃ លោកក្រាលរួចហើយ ការក្រាលកឋិន(នេះ) ប្រកបដោយធម៌ យើងសូមអនុមោទនា » ។

លុះចប់ពិធីក្រាលនេះហើយ ព្រះសង្ឃក៏សូត្រធម៌ប្រសិទ្ធពរជូនសាមីដើមទាន និងសប្បុរសជនទាំងអស់ ។ លោកអាចារ្យ ក៏នាំសូត្រធម៌ **យំ កិញ្ចិ** ... ឧទ្ទិសកុសលជូនចំពោះបុព្វការីជនដែលបានធ្វើមរណកាលទៅហើយ ជាកិច្ចបញ្ចប់ពិធីបុណ្យកឋិនទានរបស់ខ្លួន ក្នុងបរិយាកាស

សប្បាយរីករាយ និងមនោសញ្ចេតនាជ្រះថ្លាឥត ឧបមា ។

## ច. ចីវរនិងរទ្វាស់ខ្នាត

សំពត់សម្រាប់បព្វជិតស្លៀកដណ្ដប់ ហៅថា **ចីវរប្បច្ច័យ** ។ សង្ឃាដី ចីពរ ស្បង់ សំពត់ចីវរទាំង ៣នេះមានពុទ្ធានុញ្ញាតក្នុងគម្ពីរមហាវគ្គ ត្រង់ចីវរ-ក្ខន្ធកៈ ដែលអនុញ្ញាតឲ្យធ្វើចីវរប្រកបដោយខណ្ឌ មានបញ្ចខណ្ឌជាដើម គឺឲ្យប្រកបដោយឈ្មោះ ៤ យ៉ាង, អឌ្ឍ ៩ យ៉ាង, ត្រូវកាត់ឲ្យដាច់ចេញ រួចសឹម ដេរភ្ជាប់គ្នា, ធ្វើឲ្យត្រូវខ្នាត គឺកុំឲ្យធំពេក តូចពេក ។










**សត្តខណ្ឌចីវរ–ចីវរសត្តខណ្ឌ ឬចីវរមានខណ្ឌចំនួន៧**








**នវខណ្ឌចីវរ–ចីវរនវខណ្ឌ ឬចីវរមានខណ្ឌចំនួន៩**



ឯកាទសខណ្ឌចីវរ=ចីវរឯកាទសខណ្ឌ ឬចីវរមានខណ្ឌចំនួន១១





- ***ឈ្មោះចីវរ ៤ យ៉ាងគឺ***

*បញ្ចខណ្ឌ ១ សត្តខណ្ឌ ១ នវខណ្ឌ ១ ឯកាទសខណ្ឌ ១ ។ សង្ឃាដី ចីពរ ស្បង់ ដែលធ្វើដោយសំពត់ ៥ ផ្ទាំង, ក្នុងផ្ទាំងមួយៗ មានកន្ទ្បេងពីរៗ គឺកន្ទ្បេងធំ១ តូច១ ត្រូវជា ១០ កន្ទ្បេង ហៅថា **ចីវរបញ្ចខណ្ឌ** ។ ដែលធ្វើដោយសំពត់ ៧ ផ្ទាំង មានកន្ទ្បេង ១៤ ហៅថា **ចីវរសត្តខណ្ឌ** ។ ដែលធ្វើដោយសំពត់ ៩ ផ្ទាំង មានកន្ទ្បេង ១៨ ហៅថា **ចីវរនវខណ្ឌ** ។ ដែលធ្វើដោយសំពត់ ១១ ផ្ទាំង មានកន្ទ្បេង២១ ហៅថា **ចីវរឯកាទសខណ្ឌ** ។ ដេរ*

ដេរចីវរក្នុងផ្ទាំងមួយៗ[១១] ឲ្យមានកន្សែងពីរៗ ដូច្នេះ ទើបត្រូវតាមបែបក្នុងវិន័យ ។

- **អង្គចីវរ ៩ យ៉ាងគឺ**

១- **កុសិ** អនុវាតជុំវិញ និង ខ្នង់វែងៗ

២- **អឌ្ឍកុសិ** ខ្នង់ខ្លីៗ ត្រង់ចន្លោះៗ

៣- **មណ្ឌល:** កន្សែងធំវែងៗ ក្នុងខណ្ឌមួយៗ

៤- **អឌ្ឍមណ្ឌល:** កន្សែងតូចខ្លីៗ ក្នុងខណ្ឌមួយៗ

៥- **វិវដ្ដ:** ខណ្ឌកណ្ដាល

(១១) ក្នុងផ្ទាំងមួយៗ ត្រូវបែងសម្រុងជា ៣ ភាគ យកពីរភាគ ធ្វើជាមណ្ឌល: (កន្សែងធំ) គឺ បែងប្រវែងឲ្យវែងជាង អឌ្ឍមណ្ឌល: (ពីរភាគជាមួយភាគ) បែងយកមួយភាគធ្វើជាអឌ្ឍមណ្ឌល: (កន្លះភាគពីកន្សែងធំ) ។





៦- **អនុវិវដ្ដ:** ខណ្ឌទាំងពីរខាងអមបន្ទាប់ខណ្ឌកណ្ដាល[១២]

៧- **គីវេយ្យក:** សំពត់ដែលប៉ះឲ្យមាំត្រង់កន្ទៀងរុំបិទបាំងក ឬកន្សែងដែលឃ្លុំនៅត្រង់ក

៨- **ជង្ឃេយ្យក:** សំពត់ដែលប៉ះឲ្យមាំត្រង់កន្ទៀងស្មង ឬកន្សែងដែលឃ្លុំនៅត្រង់ស្មង

៩- **ពាហន្ត:** ខណ្ឌបំផុតទាំងពីរខាងត្រង់កន្ទៀងដែលឃ្លុំនៅលើដើមដៃខាងឆ្វេង ។

ចីវរដែលជាត្រូវកាត់ឲ្យដាច់ ជាកំណាត់ៗ ហើយដេរភ្ជាប់គ្នា ទើបសមគួរដល់ភេទសមណ:

(១២) បើចីវរសត្តខណ្ឌ មានអនុវិវដ្ដ: ៤ គឺម្ខាងមានពីរ ចីវរនវខណ្ឌ មានអនុវិវដ្ដ: ៦ គឺម្ខាងមានបី ចីវរឯកាទសខណ្ឌ មានអនុវិវដ្ដ: ៨ គឺម្ខាងមានបួន ។

នោះ មានពុទ្ធានុញ្ញាតថា **អនុជានាមិ ភិក្ខវេ ឆិន្នកំ សង្ឃាដឹ ឆិន្នកំ ឧត្តរាសង្គំ ឆិន្នកំ អន្តរវាសកំ** (ប្រែថា) “ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យអ្នកទាំងឡាយប្រើ) សង្ឃាដីដែលកាត់ដាច់ ចីពរដែលកាត់ដាច់ ស្បង់ដែលកាត់ដាច់” ។ ប៉ុន្តែ មានពុទ្ធានុញ្ញាតបន្ទូរមកទៀតថា បើសំពត់នោះខ្វះលៃកាត់ឲ្យដាច់ទាំង៣ ធ្វើមិនគ្រាន់ទេ នឹងកាត់ពីរមិនកាត់មួយក៏បាន បើកាត់ត្រឹមពីរហើយនៅតែខ្វះធ្វើមិនគ្រាន់ទៀត នឹងកាត់តែមួយមិនកាត់ពីរក៏បាន (មានពុទ្ធប្បញ្ញត្តិមិនឲ្យខានកាត់ទាំង៣) បើភិក្ខុប្រើប្រាស់ចីវរមិនកាត់ទាំង ៣ ត្រូវអាបត្តិទុក្កដ ។





ឯថ្នេរដែលដេរភ្ជាប់គ្នាគ្រប់ខណ្ឌ គ្រប់កន្សែងជាខ្នង់នោះ ត្រូវដេរជាថ្នេរតូចៗកុំឲ្យពាក់ប្រក់តម្រួតលើគ្នាជាពីរជាន់ គឺត្រង់ផ្នែកក្នុងខ្នង់តូចៗនោះត្រូវធ្វើតែមួយជាន់ស្មើគ្នាទាំងអស់ លើកតែអនុវាតជុំវិញចេញ ដ្បិតមានពុទ្ធានុញ្ញាតថា **ឯកច្ចិយំ ឧត្តរាសង្គំ ឯកច្ចិយំ អន្តរវាសកំ** “ចីពរដេរមួយជាន់ ស្បង់ដេរមួយជាន់” ដូចគ្នា ចំណែកខណ្ឌនិងកន្សែងរបស់ស្បង់ក៏ដូចគ្នានឹងចីពរដែរ ។ ក្នុងយោជនាដីកាវិន័យ មានសេចក្ដីពន្យល់អំពីការដេរថ្នេរចីពរ និងស្បង់នោះដោយសេចក្ដីជាក់ច្បាស់ថា **អាទិសទ្ទេន ទ្វិន្នំ ខណ្ឌានំ អន្តរា មាតិកាសណ្ឋានេន ឋបិតបដញ្ច ទីឃបដញ្ច ទដ្ឋព្វំ** ។

(ប្រែថា) តាម**អាទិសព្ទ** គឺសព្ទដែលប្រែថា″ជាដើម″ បណ្ឌិតគប្បីជ្រាបថា សំពត់ដែលគេដេរ ដោយសណ្ឋាន ដូចជាសណ្ឋានរបស់ប្រឡាយទឹក ត្រង់ចន្លោះនៃខណ្ឌទាំងពីរ គឺខ្នង់វែងៗ(ទាំងប៉ុន្មាន)ក្តី សំពត់អនុវាតវែងៗ(ទាំងប៉ុន្មាន) ក្តី (ហៅថាកុសិ) ។ សង្ឃាដីត្រូវធ្វើពីរជាន់ ចីពរមួយជាន់ ស្បង់មួយជាន់ បើសង្ឃាដីបួនជាន់ ចីពរត្រូវធ្វើពីរជាន់ ស្បង់ពីរជាន់ ដោយពុទ្ធានុញ្ញាតថា **អនុជានាមិ ភិក្ខវេ អហតានំ ទុស្សានំ អហតកប្បានំ ទ្វិគុណំ សង្ឃាដឹ ឯកច្ចិយំ ឧត្តរាសង្គំ ឯកច្ចិយំ អន្តរវាសកំ ឧតុទ្ធតានំ ទុស្សានំ ចតុគ្គុណំ សង្ឃាដឹ ទ្វិគុណំ ឧត្តរាសង្គំ ទ្វិគុណំ អន្តរវាសកំ បំសុកូលេ យាវទត្ថំ**





**បាបណិកេ ឧស្សាហោ ករណីយោ អនុជានាមិ ភិក្ខវេ អគ្គឡំ តុន្នំ ឱវដ្ដិកំ កណ្ឌុសកំ ទឡ្ហីកម្មំ ។** (ប្រែថា) ″ម្នាលភិក្ខុទាំងឡាយ កាលបើសំពត់នៅថ្មី ឬសំពត់ដែលគេទើបនឹងគក់ម្តង តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយ ធ្វើសង្ឃាដីពីរជាន់ ចីពរមួយជាន់ ស្បង់មួយជាន់ បើសំពត់នោះចាស់ តថាគតអនុញ្ញាតឲ្យធ្វើសង្ឃាដីបួនជាន់ ចីពរពីរជាន់ ស្បង់ពីរជាន់ អ្នកទាំងឡាយគួរស្វែងរកសំពត់បង្សុកូល សំពត់ដែលធ្លាក់ចុះចាកពានផ្សារ តាមត្រូវការចុះ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យអ្នកទាំងឡាយប៉ះជួស ដាក់ក្រវិលក្តុំ និងដាក់អន្ទាក់ក្តុំ ធ្វើឲ្យមាំមួន″ ។ ខ្នាតចីវរ ដែលថា

ធ្វើឲ្យត្រូវនឹងប្រមាណកុំឲ្យធំពេក តូចពេកនោះ គឺធ្វើកុំឲ្យធំប៉ុនចីវរព្រះសុគត ។ ខ្នាតចីពរ សង្ឃាដី ព្រះសុគត បណ្តោយ ៩ ចំអាម ទទឹង ៦ ចំអាម ដោយចំអាមព្រះសុគត បើគិតជាហត្ថជាងឈើ បណ្តោយ ១៣ ហត្ថ ១ ចំអាម ទទឹង ៩ ហត្ថ ។ សេចក្តីនេះពោលតាមពាក្យ ព្រះអដ្ឋកថាចារ្យ ដែលសម្តែងទុកក្នុងគម្ពីរ ទុតិយសមន្តប្បាសាទិ-កាអដ្ឋកថា ថា **តស្ស បមាណំ ឧក្កដ្ឋបរិច្ឆេទេន សុគតចីវរតោ ឩនកំ វដ្តតិ ។ លាមកបរិច្ឆេទេន ច សង្ឃាដិយា ច ឧត្តរាសង្គស្ស ច ទីឃតោ មុដ្ឋិបញ្ចកំ តិរិយតោ មុដ្ឋិតិកំ បមាណំ វដ្តតិ ។ អន្តរវាសកោ ទីឃតោ មុដ្ឋិបញ្ចកោ តិរិយំ ទ្វីហត្ថោបិ វដ្តតិ ។**





**វុត្តប្បមាណតោ បន អតិរេកញ្ច ឩនកញ្ច បរិក្ខារចោឡន្តិ អធិដ្ឋាតព្វំ ។** សេចក្តីថា ចីវរត្រូវធ្វើឲ្យតូចជាងចីវរព្រះសុគតទើបប្រើប្រាស់បាន ។ ខ្នាតចីពរសង្ឃាដីយ៉ាងតូចបំផុត ត្រូវធ្វើបណ្តោយ ៤ ហត្ថ ១ គក់ ទទឹង ២ ហត្ថ ១ គក់ ខ្នាតស្បង់បណ្តោយ ៤ ហត្ថ ១ គក់ ទទឹង ២ ហត្ថ ។ បើត្រៃចីវរដែលមានខ្នាតធំ ឬតូចជាងខ្នាតដែលនិយាយមកនេះ អធិដ្ឋានមិនឡើងជា ចីពរ ស្បង់ សង្ឃាដីឡើយ ត្រូវអធិដ្ឋានចេញឈ្មោះជាបរិក្ខារចោឡៈ ទើបប្រើប្រាស់បាន ។

អំពីទំហំអនុវាតនិងខ្នង់ចីវរទាំងនេះ មិនឃើញមានបញ្ញត្តិឲ្យធ្វើទំហំប៉ុន្មានៗ ជាដាច់ខាត

ទេ ប៉ុន្តែមានសេចក្តីក្នុងអដ្ឋកថាចីវរក្ខន្ធកៈប្រាប់អំពីវិធីចែកសំពត់ថា បើសំពត់តិច ភិក្ខុចែកគ្នាមិនគ្រាន់ ត្រូវឲ្យកាត់ប្រៀកជាចម្រៀកៗយ៉ាងតូចបំផុតខាងទទឹង ៤ ធ្នាប់ ខាងបណ្តោយលៃឲ្យល្មមធ្វើអនុវាតបាន ។ សេចក្តីនេះ សឲ្យឃើញថាអនុវាតចីវរ យ៉ាងតូចបំផុតទំហំត្រឹម ៤ ធ្នាប់ក៏ប្រើបាន ។ ឧត្តរាសង្គៈនិងសង្ឃាដី បើធ្វើអនុវាតទំហំ ១៥ សង់ទីម៉ែត្រ ខ្ពង់ទំហំ ៥ សង់ទីម៉ែត្រ ស្បង់ធ្វើអនុវាតទំហំ ៨ ឬ ៩ សង់ទីម៉ែត្រ ខ្ពង់ទំហំ ៤ ឬ ៥ សង់ទីម៉ែត្រកន្ទះ នេះល្មមមិនធំពេក មិនតូចពេកៗ ដំណើរនេះ អ្នកស្ទាត់ក្នុងការលៃលកគួរលៃកាត់ឲ្យល្មមសមរម្យចុះ ៕





## ឆ. អានិសង្សចីវរទាន

### រឿងស្ត្រីអ្នកក្រីក្រ

ក្នុងអតីតកាល ក្នុងទីក្រុងពារាណសី ស្ត្រីអ្នកក្រីក្រម្នាក់ ឃើញស្ត្រីទាំងឡាយ ដែលបរិបូណ៌ដោយបុណ្យ ស្លៀកសំពត់ដែលជ្រលក់ដោយផ្កាដកគាំ កំពុងលេងក្នុងថ្ងៃមហោស្រព ជាអ្នកប្រាថ្នានឹងស្លៀកសំពត់ដូច្នេះ ហើយលេង(នឹងគេ) បានប្រាប់ដល់មាតាបិតា កាលបើមាតាបិតា ពោលថា "នែកូនស្រី ពួកយើងជាអ្នកក្រីក្រ សំពត់បែបនេះនឹងមានដល់ពួកយើង អំពីណាមក ?" ដូច្នេះ ទើបពោលថា "បើដូច្នោះ នាងខ្ញុំនឹងធ្វើនូវការស៊ីឈ្នួលក្នុងត្រកូលអ្នកស្តុកស្តម្ភមួយ អ្នកទាំងនោះដឹងនូវ-

គុណរបស់ពួកយើងហើយក៏នឹងឲ្យ” ដូច្នេះ ហើយបានចូលទៅរកត្រកូលមួយ ពោលថា “នាងខ្ញុំនឹងធ្វើនូវការស៊ីឈ្នួល ព្រោះសំពត់ក្រហម ដែលជ្រលក់ដោយផ្កាដកគាំ” ។ ជនក្នុងត្រកូលទាំង-នោះ ពោលថា “កាលបើនាងធ្វើការងារ រហូត ៣ ឆ្នាំហើយ ពួកយើងនឹងឲ្យដល់នាង” ។ ស្ត្រីអ្នកក្រីក្រនោះ ទទួលព្រមថា “ល្អហើយ” ហើយបានធ្វើការងារ ។ កាលបើ ៣ ឆ្នាំ មិនទាន់គ្រប់បរិបូណ៌ហើយទុំះឯង ពួកជនទាំងនោះដឹងនូវគុណរបស់នាង ហើយក៏បានឲ្យហើយនូវសំពត់សូម្បីឯទៀតព្រមទាំងសំពត់ក្រហម ដែលជ្រលក់ដោយផ្កា-កុសុម្ភៈ ដែលមានសាច់ក្រាស់ដល់ស្ត្រីនោះ ។ ស្ត្រី





អ្នកក្រីក្រនោះ បានទៅហើយដាក់នូវសំពត់ពណ៌ក្រហមនៅក្បែរមាត់ស្ទឹង ហើយចុះងូតទឹក ។ ក្នុងខណៈនោះ សាវ័ករបស់ព្រះមានព្រះភាគ ព្រះ-នាមកស្សបៈ មួយអង្គមានចីវរត្រូវចោរលួចយកទៅ ស្បៀកនិងគ្រងនូវមែកឈើដែលកាច់មកហើយ បានមកដល់ប្រទេសនោះ ។ នាងគិតថា “ភិក្ខុរូបនេះ នឹងមានចីវរត្រូវចោរលួចយកហើយសំពត់សម្រាប់ស្បៀករបស់អាត្មាអញ ជារបស់ដែលរកបានដោយកម្រ ព្រោះអាត្មាអញមិនបានឲ្យហើយក្នុងកាលមុន” ដូច្នេះហើយ ក៏បានហែកសំពត់នោះ ត្រង់ពាក់កណ្ដាល បានប្រគេនសំពត់មួយកំណាត់ ដល់ព្រះថេរៈនោះ ។ ព្រះថេរៈ ឈរ

នៅក្នុងទីបិទបាំង ចោលមែកឈើដែលកាចហើយ ក៏ស្លៀកកំណាត់សំពត់នោះ មួយចម្រៀក គ្រងមួយចម្រៀក និមន្តចេញទៅហើយ ។ គ្រានោះ សរីរៈទាំងអស់របស់ព្រះថេរៈ បានមានរស្មីភ្លឺតែមួយ ដូចជាព្រះអាទិត្យដែលខ្ចី ព្រោះអានុភាពនៃសំពត់ ។ នាងបានឃើញព្រះថេរៈនោះហើយ ក៏គិតថា "ជាដំបូង ព្រះគុណម្ចាស់របស់អាត្មាអញមិនស្រស់ទេ (តែ) ឥឡូវនេះ រមែងរុងរឿង ដូចជាព្រះអាទិត្យដែលខ្ចីៗ អាត្មាអញនឹងប្រគេននូវសំពត់នេះ ដល់ព្រះគុណម្ចាស់នុ៎ះឯង" ដូច្នេះហើយ ក៏បានប្រគេននូវចំណែកទី ២ ហើយបានធ្វើសេចក្តីប្រាថ្នាថា "បពិត្រព្រះគុណម្ចាស់ នាងខ្ញុំ





កាលត្រាច់រង្គាត់ទៅក្នុងភព គប្បីជាអ្នកទ្រទ្រង់នូវរូបដ៏ស្រស់ បុរសឯណាមួយ បានឃើញនាងខ្ញុំហើយ មិនអាចដើម្បីនឹងស្ថិតនៅដោយភាពរបស់ខ្លួនបានឡើយ ស្រ្តីឯទៀតៗ ឈ្មោះថា ជាអ្នកមានរូបល្អស្អាតជាងនាងខ្ញុំ កុំបីមានឡើយ" ។ ឯព្រះ-ថេរៈបានធ្វើអនុមោទនាហើយ ក៏ចៀសចេញទៅ។ នាងកាលអន្ទោលទៅកាន់ទេវលោក ច្យុតអំពីទេវ-លោកនោះហើយ បានមកកើតជាធីតា របស់សេដ្ឋីអ្នកមានភោគសម្បត្តិ ៨០ កោដិ ឈ្មោះថាតិរិដិវច្ឆៈក្នុងអរិដ្ឋបុរី ក្នុងសិរិរដ្ឋ ។ នាងធីតានោះជាអ្នកទ្រទ្រង់រូបដ៏ស្រស់ ដល់នូវភាពជាអ្នកល្អប្រសើរលើសដោយសេចក្តីសោភា ញ៉ាំងបុរសអ្នកដែល

ឃើញខ្លួននាង ឲ្យវង្វេងវង្វាន់និងមិនឲ្យបុរសនោះតាំងសតិស្មារតីបានឡើយ ។ ព្រោះហេតុនោះ ជនទាំងឡាយទើបបានតាំងឈ្មោះឲ្យនាងថា "នាងឧម្មាទន្តី" ។ ក្នុងពេលដែលនាងមានអាយុ ១៦ ឆ្នាំ នាងមានពណ៌សម្បុរល្អកន្លង ពណ៌សម្បុរនៃមនុស្ស ប្រៀបដូចជានាងទេពអប្សរ ។ ពួកបុថុជ្ជនណាៗ ឃើញនូវនាងឧម្មាទន្តីនោះ ពួកបុថុជ្ជននោះៗ មិនអាចដើម្បីនឹងស្ថិតនៅ ដោយភាវៈនៃខ្លួនបានជាអ្នកស្រវឹងហើយ ដោយសេចក្តីស្រវឹងព្រោះកិលេស ដូចជាស្រវឹងព្រោះគ្រឿងស្រវឹង មិនអាចដើម្បីផ្ទង់សតិ ឲ្យស្ថិតនៅបានឡើយ ។ លោកសេដ្ឋីតិរិដិវច្ឆៈ បានចូលទៅគាល់ព្រះបាទ





សិវិរាជហើយ ក្រាបទូលថា "បពិត្រព្រះសម្មតិទេព ឥត្ថីរត្ន កើតឡើងហើយក្នុងផ្ទះនៃទូលព្រះបង្គំ ជាអ្នកសមគួរដល់ព្រះអង្គតែប៉ុណ្ណោះ សូមព្រះអង្គទ្រង់បញ្ជូនអ្នកទាយនូវលក្ខណៈទៅ ហើយទ្រង់ឲ្យត្រួតពិនិត្យមើលនូវស្ត្រីរត្ននោះ" ។ ព្រះរាជាទ្រង់បានបញ្ជូនពួកព្រាហ្មណ៍ទៅ ។ ព្រាហ្មណ៍ទាំងនោះទៅហើយ ត្រូវសេដ្ឋីធ្វើសក្ការៈនិងសេចក្តីរាក់ទាក់ហើយបរិភោគ ។ ក្នុងខណៈនោះ នាងឧម្មាទន្តី ទៅកាន់សំណាក់របស់ព្រាហ្មណ៍ទាំង-នោះ ។ ព្រាហ្មណ៍ទាំងនោះ បានឃើញនាងហើយ ក៏មិនអាចដើម្បីនឹងតាំងសតិស្មារតីនៅបាន ជាអ្នកវង្វេងដោយសេចក្តីវង្វេងព្រោះកិលេស មិនដឹងនូវ

ការបរិភោគដែលខុសប្រក្រតីរបស់ខ្លួន ពួកខ្លះយកពំនូតបាយ ដាក់លើក្បាល ដោយគិតថា "នឹងបរិភោគ" ដូច្នេះ ពួកខ្លះធាក់ជញ្ជាំង ពួកខ្លះញាត់ពំនូតបាយ ក្នុងចន្លោះរន្ធត្រចៀកពួកព្រាហ្មណ៍ទាំង-អស់ បានជាអ្នកច្ឆួតវង្វេងហើយ ។ នាងឧម្មាទន្តីបានឃើញពួកព្រាហ្មណ៍ទាំងនោះហើយ ក៏បានឲ្យគេបណ្តេញចេញទៅ ដោយពាក្យថា "បានឮថា ពួកព្រាហ្មណ៍ទាំងនេះ នឹងពិចារណានូវលក្ខណៈរបស់ខ្ញុំ ចូរអ្នកទាំងឡាយ ចាប់ព្រាហ្មណ៍ទាំងនេះ ត្រង់កហើយហើយបណ្តេញចេញទៅ"។ ព្រាហ្មណ៍ទាំងនោះ ជាអ្នកខ្មាសអៀនហើយក្រោធខឹងចំពោះនាងក្រាបទូលថា "បពិត្រព្រះ-





សម្មតិទេព ស្ត្រីនោះ ជាអ្នកកាឡកណ្ណីមិនសមគួរដល់ព្រះអង្គឡើយ" ។ ចំណែកព្រះរាជា មិនបានត្រាស់បញ្ជា ឲ្យនាំយកនាងឧម្មាទន្តីនោះមកទេ ព្រោះទ្រង់សម្គាល់ថា "បានឮថា នាងជាស្ត្រីកាឡកណ្ណី" ។ ឯនាងឧម្មាទន្តីនោះ ស្តាប់រឿងនោះហើយបានចងអាឃាត ចំពោះព្រះរាជាអង្គនោះថា "រឿងនោះលើកទុកសិនចុះ បើអាត្មាអញចូលគាល់ព្រះរាជអង្គនោះ ក៏គង់តែដឹង" ។ គ្រានោះសេដ្ឋីបានលើកនាងឲ្យដល់សេនាបតី ឈ្មោះអភិបារកៈ ជាសម្លាញ់របស់ព្រះរាជា ។ នាងបានជាទីស្រឡាញ់ពេញចិត្ត របស់សេនាបតីនោះ ។ ក្រោយមក ថ្ងៃមួយ សេនាបតីកាលទៅកាន់ទីរក្សា

របស់ខ្លួន បានពោលថា "នែនាងដ៏ចម្រើន ថ្ងៃនេះជាថ្ងៃមហោស្រព ពេញបូណ៌មី ខែកត្តិក ព្រះរាជានឹងទ្រង់ធ្វើប្រទក្សិណព្រះនគរ ទ្រង់ស្ដេចយាងមកកាន់ទ្វារផ្ទះនេះ ជាបឋម ចូរនាងកុំបង្ហាញខ្លួនដល់ព្រះរាជាអង្គនោះឡើយ ព្រោះព្រះរាជាអង្គនោះ ឃើញប្អូនហើយក៏នឹងមិនអាចដើម្បីទ្រង់តាំង ព្រះសតិស្មារតីឲ្យស្ថិតនៅបាន" ដូច្នេះហើយ ទើបគេចចេញទៅ ។ ចំណែកព្រះរាជា កាលបើព្រះអាទិត្យអស្តង្គតទៅហើយ កាលបើព្រះច័ន្ទពេញវង់ រះឡើងហើយ ទ្រង់ធ្វើប្រទក្សិណព្រះ-នគរដោយយសបារមីដ៏ធំ ទ្រង់ស្ដេចយាងទៅកាន់មាត់ទ្វារផ្ទះ របស់សេនាបតីជាបឋមភ្លាម ទ្រង់បាន





ទតព្រះនេត្រឃើញនាងឧម្មាទន្តី ឈរនៅក្បែរបង្អួច ទ្រង់ជាអ្នកឆ្កួតវង្វេង ដោយសេចក្ដីឆ្កួតវង្វេង ព្រោះកិលេសមិនអាចដើម្បីនឹងទ្រង់តាំងព្រះសតិឲ្យស្ថិតនៅបាន មិនទ្រង់ញ៉ាំងព្រះទ័យ ក្នុងការធ្វើប្រទក្សិណព្រះនគរឲ្យកើតឡើង ទ្រង់ស្ដេចត្រឡប់អំពីទីនោះ ហើយស្ដេចឡើងកាន់ប្រាសាទ ទ្រង់ព្រះបន្ទំ រវើរវាយ ប្រារព្ធនាងឧម្មាទន្តី ដោយប្រ-ការផ្សេងៗ ។ សេនាបតី ដឹងរឿងនោះហើយ ក៏គិតថា "ព្រះរាជាអង្គនេះ ទ្រង់មានព្រះទ័យប្រតិព័ទ្ធចំពោះនាងឧម្មាទន្តី កាលទ្រង់មិនបានក៏នឹងទ្រង់ទិវង្គត ការដែលអាត្មាអញ ថ្វាយជីវិត ដល់ព្រះ-អង្គទើបសមគួរ" ដូច្នេះហើយ បានបង្គាប់ឧបដ្ឋាក

ម្នាក់ ថា "អ្នកចូរទៅ រុក្ខចេតិយដែលមានប្រហោង ក្នុងទីឯណោះមាន ចូរអ្នកកុំឲ្យអ្នកឯណាមួយដឹង ហើយអង្គុយ ពួន់ខាងក្នុងនៃដើមឈើ ខ្ញុំទៅក្នុងទីនោះហើយក៏នឹងធ្វើនូវពលីកម្ម ហើយពោលយ៉ាងនេះ គ្រានោះ អ្នកចូរពោលយ៉ាងដូច្នេះ" ។ ឧបដ្ឋាកនោះ ពោលថា "ប្រពៃណាស់" ហើយក៏បានទៅក្នុងទីនោះ ។ ចំណែកសេនាបតី លុះស្អែកឡើង ក៏បានទៅក្នុងទីនោះ ធ្វើពលីកម្មស្រេចហើយ ក៏ពោលថា "បពិត្រទេវតា ព្រះរាជារបស់ពួកយើងខ្ញុំ កាលបើមហោស្រពកំពុងតែប្រព្រឹត្តទៅ មិនទ្រង់ព្រះក្រសាល ស្តេចយាងចូលព្រះក្រឡាបន្ទំដ៏មានសិរី ទ្រង់ផ្ទំ រវើរវាយហើយ ព្រះអង្គ





ទ្រង់រវើរវាយ ព្រោះអាស្រ័យរឿងអ្វី?" ។ ឧបដ្ឋាកនោះ ប្រែសំឡេងហើយ ពោលថា "ម្នាលសេនា-បតី ព្រះរាជារបស់ពួកអ្នក ទ្រង់មានព្រះហឫទ័យប្រតិព័ទ្ធចំពោះនាងឧម្មាទន្តី ដែលជាភរិយារបស់លោក បើព្រះអង្គនឹងបាននាងឧម្មាទន្តីនោះ នឹងមិនទ្រង់ចូលទិវង្គត បើនឹងមិនបានទេក៏នឹងទ្រង់ចូលទិវង្គត ព្រោះហេតុនោះ ចូរអ្នកថ្វាយនាងឧម្មាទន្តីនោះ ដល់ព្រះរាជាអង្គនោះ" ។ សេនាបតីពោលថា "ល្អណាស់" ហើយបានចូលទៅគាល់ព្រះរាជា ក្រាបទូលរឿងនោះ ហើយក្រាបទូលថា "បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំ សូមថ្វាយនាងឧម្មាទន្តីដល់ព្រះអង្គ" ។ ព្រះរាជាទ្រង់ត្រាស់

សួរថា "នែអភិបារកៈ អ្នកជាសម្លាញ់ សូម្បីពួកយក្ស រមែងដឹងនូវភាវៈនៃខ្ញុំជាអ្នករើរវាយព្រោះមានចិត្តប្រតិព័ទ្ធ ចំពោះនាងឧម្មាទន្តីឬ ?" ។ សេនាបតី ក្រាបទូលថា "បពិត្រព្រះសម្មតិទេពពិតមែនហើយ" ។ ព្រះរាជាទ្រង់ ព្រះតម្រិះ ថា "បានឮថា ភាវៈនៃអាត្មាអញជាអ្នកលាមក ប្រជាលោកគ្រប់គ្នា បានដឹងអស់ហើយ" ដូច្នេះ ទ្រង់អៀនខ្មាសព្រះទ័យ ទ្រង់តាំងនៅហើយក្នុងធម៌ ទ្រង់បន្ទោបង់ហើយនូវព្រះទ័យ ប្រតិព័ទ្ធចំពោះនាងឧម្មាទន្តី ទ្រង់មិនបានទទួលយកនូវនាងឧម្មាទន្តីនោះទេ ។ រឿងស្ត្រីក្រីក្រ មានក្នុងអដ្ឋកថាឧម្មាទន្តីជាតក ក្នុងបញ្ញាសនិបាត ៕





## ឯកសារពិគ្រោះ

- បិដកភាគ ៨ កឋិនខន្ធកៈ និងចីវរក្ខន្ធកៈ
- បិដកភាគ ១៣ បរិវារ
- សមន្តប្បាសាទិកា
- វិនយាលង្ការដីកា
- កឋិនកថាសង្ខេប
- ទានកថា
- កឋិនវិនិច្ឆ័យ
- កម្ពុជសុរិយា
- និង វចនានុក្រម (សម្តេចសង្ឃរាជ ជោតញ្ញាណោ **ជួន ណាត**)

## អ្នកមានឧបការៈក្នុងការចោរធម្មទាន

- ភិក្ខុ វង្ស សំអឿន
- សាមណេរ អគ្គសិរីវិមលញ្ញាណ លី ប៊ុនលីន
- ឧបាសក ចាន់ សុជិន(កែវ) ផ្នែកការីកុំព្យូទ័រ
- យុវជន ចាន់ ករុណា និស្សិតសកលវិទ្យាល័យភូមិន្ទភ្នំពេញ
- ឧបាសក ធន ជិនជាលី
- ឧបាសក សួន សិរី

**សព្វទានំ ធម្មទានំ ជិនាតិ**

**ធម្មទានឈ្នះអស់ទានទាំងពួង**





## ស្ថានីយ៍វិទ្យុ ផ្សព្វផ្សាយព្រះធម៌ព្រះពុទ្ធសាសនា

## ដែលសម្តែងដោយ ខ្ញុំព្រះករុណា~អាត្មាភាព ចាន់ សុជន

| ខេត្ត~ក្រុង | វេលាផ្សាយ | ស្ថានីយ៍វិទ្យុ |
|---|---|---|
| ភ្នំពេញ | ៥:០០ ព្រឹក | FM ៩១.០០ MHz |
| | ៦:០០ ល្ងាច<br>អង្គារ, ពុធ, ព្រហស្បតិ៍ | FM ៨៧.០៥ MHz |
| បន្ទាយមានជ័យ | ៥:៣០ ព្រឹក | FM ៩៩ MHz |
| | ១២:០០ ថ្ងៃត្រង់<br>ផ្សាយបន្តផ្ទាល់ | FM ១០៦.៥ MHz |
| ប៉ោយប៉ែត | ៦:០០ ល្ងាច | FM ៩៨.៣ MHz |
| កំពង់ធំ | ៥:៣០ ព្រឹក | FM ៩៨.៣ MHz |
| ឧត្តរមានជ័យ | ៥:៣០ ព្រឹក | FM ៩០.៥ MHz |

# សៀវភៅដែលរៀបរៀងដោយ

## ខ្ញុំព្រះករុណា អាត្មាភាព

## ✍ចាន់ សុជន ✍

១- ជំនួយសុខភាពផ្លូវចិត្ត ភាគ ១ ដល់ភាគ ៤

២- ពុទ្ធសាសនាសម្រាប់អ្នកសិក្សាដំបូង (Buddhism for beginner)

៣- សំណួរ ចម្លើយកម្មផល (Question-Answer action and result)

៤- កម្រងនៃទម្លាប់ល្អ (Garland of good habits)

៥- មូលដ្ឋានគ្រឹះព្រះពុទ្ធសាសនា

៦- សំណួររបស់ខ្ញុំ-ចម្លើយរបស់អ្នក

៧- ហេតុផល ក្នុងព្រះពុទ្ធសាសនា (The Cause and Effect in Buddhism)

៨- យល់ដឹងពីការចូលវស្សា ដង្ហែទៀនវស្សា និងសាដក





# នាមពុទ្ធបរិស័ទមានសទ្ធាចូលរួមបោះពុម្ព

| | | |
|---|---|---|
| ០១- | ប្រាក់បូជាព្រះធម៌ សម្តែងដោយព្រះគ្រូធម្មាលង្ការោ *ចាន់ សុជន* | $ ១០០ |
| ០២- | ភិក្ខុ ម៉ុន សាយ ចៅអធិការវត្តខ្មែរស្រីលង្កា ........... | $ ១០០ |
| ០៣- | ភិក្ខុ ឡុង សុភាព ........................................... | $ ១០០ |
| ០៤- | ឧ.សិ. គីម សុវណ្ណ ប្រទេសអូស្ត្រាលី ................... | $ ២០០ |
| ០៥- | ឧ.សិ. ឡេង ឈុនគួយ....................................... | $ ១០០ |

## <u>ទឹកប្រាក់ចូលតាមរយៈ</u>

| | | |
|---|---|---|
| ០៦- | លោកម្ចាស់ ជឿន សុជាតិ ................ | |
| ០៧- | ព្រះសង្ឃវត្តខ្វាស់ ............................. | |
| ០៨- | ឧ.សិ. ជាម សី លួត (ស្តៅ) ................ | |
| ០៩- | ឧ.សិ. វរលក្ខណ៍ (ស្វាយ.ស)............. | $ ២០០ |
| ១០- | ឧ.សិ. ភុំ ផាន .................................. | |
| ១១- | ឧ.សិ. ផល ឈឿត ........................ | |
| ១២- | ឧ.សិ. ចាន់ រ៉ា .................................. | |
| ១៣- | កញ្ញា គី លី .................................... | $ ៥ |

**បោះពុម្ពលើកទី១ចំនួន ១,៥០០ក្បាល**

**ក្នុងតម្លៃ ,,,,,,,,,,,,,,,,៛**